# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៦ ខែធ្នូ លេខ ១២

ព.ស. ២៤៩៧ _ គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*


— សត្វាទេវមនុស្សាន៌ ............ ព្រះធម្មបាលិវង្ស ម៉ុង - សែស ... ៨៨៣

— បញ្ញាសជាតក ភាគទី ៣ (តមក). ... បណ្ឌិតមហា ឈឹម -ស៊ុម..... ៨៩៦


*ផ្នែកអក្សរសាស្ត្រ*


— រឿងសៅរសោយ (តមក) ....... . ព្រះមហាធម្មអវិជ្ជា ប៊ុង—ប៉ម ... ៩០៨

— រឿងសាមកុក (តមក)..... .... ឧកញ៉ា ទូ- កន ........ ៩១៣

— ទាលះនិងទមយន្តី (តចប់) ....... អ្នកស្រី ស្រីន—សារីយ៉ាន ... ៩១៨

— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក)... លោក ផេង - ជ្រីវ ......... ៩២៩

— រឿងបល្ល័ង្កទិព្យ (តមក)......... លោកភ៊ាយ - ប៊ុក ......... ៩៣៤


*កំណត់នឹងប្រវត្តិការណ៍*


— ដំណើរទៅកាន់ប្រទេសភូមា (ត- ចប់).. ព្រះទេពសត្ថា កិម- ទូរ..... ៩៣៩

— បញ្ជីរាយនាមចៅអធិការដែលទើបតាំងថ្មី. (តមក) ក្រសួងធម្មការ...... ៩៥៩


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០៛.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Satthadevamenussanam . . . *vén. MENG-SES* . . . . . . . 883

— Pannasajataka- vol 3 (suite) . *M CHHIM-SOUM* . . . . . . . 896

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence saturnienne (suite) . . . . . *vén. PEUNC-PAM* . . . . . . 908

— Histoire de samkok (suite). . *oknha NOU-KAN* . . . . . . 913

— Nala et Damayanti (suite et fin) *Mme SRIN-SARIS-YANN* . . . 918

— Le souffle du désert (suite) . . *M. PHENG-CHRIV* . . . . . . 929

— Les trente deux récits du TRONE (suite) . . . . . . *M. RAY - BUC* . . . . . . . . 934

NOTES ET CHRONIQUES:

— Le voyage en Birmanie (suite et fin) *Brah Debasatha KEM-TO*. 939

— La nomination des nouvaux chau-Adhikar (suite) . . . . . . . . *Ministère des Cultes* . . . 959

Prix d'abonnement annuel (comprenant 12 numéros) 200$00

# សូមជូនដំណឹង

## អំពីទស្សនាវដ្តីកម្ពុជសុរិយា ផ្សាយចេញ

## អំពីពុទ្ធសាសនបណ្ឌិត្យ

---

ទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៤ ដែលអស់លោក-អ្នក បានចុះឈ្មោះជាវមកនោះ នឹងចប់ត្រឹមខ្សែលេខ ១២ នេះហើយ ។ យើងសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ចំពោះអស់លោក-អ្នកដែលបានចុះឈ្មោះជាវទាំងនោះ ហើយមានសង្ឃឹមថា អស់លោក អ្នកនឹងចុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយាក្នុងឆ្នាំ ១៩៥៥ តទៅទៀត ដែលយើងកំពុងរៀបរៀងនឹងប្រមូលផ្តុំរឿងរ៉ាវនឹងបោះពុម្ព ។ កិច្ចដែលអស់លោក-អ្នកចុះឈ្មោះជាវច្រើនឡើង ៗ នេះ ឈ្មោះថាជាការជួយឧបត្ថម្ភអក្សរសាស្ត្រខ្មែរឲ្យលូតលាស់ចំរើនឡើង ទាំងឈ្មោះថាជាការជួយឲ្យកម្លាំងនឹងលើកតំកើងនូវពួកអ្នកនិពន្ធខ្មែរយើង ។

តាមការណ៍ពិត ទស្សនាវដ្តីកម្ពុជសុរិយានេះ ជាទស្សនាវដ្តីផ្ទុកការផ្សាយចេញនូវរឿងរ៉ាវផ្នែកសាសនានឹងអក្សរសាស្ត្រ ទុកដូចជាប្រទីបសម្រាប់បំភ្លឺប្រជាជនរួមជាតិឲ្យមានបញ្ញាចក្ខុ មើលឃើញច្បាស់នូវសេចក្តីវិនាសនឹងសេចក្តីចំរើនក្នុងផ្លូវលោកនឹងផ្លូវធម៌ ព្រមទាំងពង្រីកអក្សរសាស្ត្រជាតិឲ្យរីកធំទូលាយតាមសម័យ ។

ឯរឿងរ៉ាវក្នុងផ្នែកសាសនានិងអក្សរសាស្ត្រ ដែលយើងនឹងបោះពុម្ពផ្សាយក្នុង ទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ១៩៥៥ ដូចមានរាយមាតិកាតទៅនេះ ៖

## ផ្នែកសាសនា

១ – ដំណឹងផ្សេង ៗ ខាងព្រះពុទ្ធសាសនា ។

២ – ធម្មទេសនា ដែលមានអត្ថរសប្លែក ៗ ។

៣ – សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ – ការជ្រើសរើសប្រែព្រះសូត្រខ្លះ ដែលមានសេចក្ដីគួរដើម្បីនិងជាផ្លូវប្រតិបត្តិ ។

## ផ្នែកអក្សរសាស្ត្រ

១ – គោលបារិកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងកាព្យឃ្លោងចាស់ ៗ ឬថ្មីទើប ។

២ – ឯកសារ (រឿងរ៉ាវសំខាន់ ៗ ដូចសិលាចារិកជាដើម) ។

៣ – រឿងសាមកុក នៅតែបោះពុម្ពតទៅទៀត គ្រាតែចប់ ។

៤ – សុភាសិតផ្សេង ៗ របស់ជាតិយើងនិងនានាជាតិ ។

៥ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៦ – រឿងទំនៀមទម្លាប់ខ្មែរ របស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ ។ល។

*ហេតុនេះ អស់លោក-អ្នកដែលមានបំណងនឹងជាវទស្សនាវដ្ដីកម្ពុជសុរិយាប្រចាំឆ្នាំ ១៩៥៥ សូមផ្ញើឈ្មោះពីឥឡូវនេះទៅ* អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ (Monsieur le Secrétaire Général de l'Institut Bouddhique Phnom-Pénh) *ដោយមានចុះនាមទីលំនៅ ព្រមទាំងដំឡៃជាវប្រចាំឆ្នាំចំនួន ២១០ រៀលផង ។*

ពុទ្ធសាសនបណ្ឌិត្យ

---

ជាតិខ្មែរអាស្រ័យយើង

បើស្រឡាញ់កូន ត្រូវស្រឡាញ់ជាតិ,
បើស្រឡាញ់ជាតិ ត្រូវស្រឡាញ់អក្សរសាស្ត្រ,
តែកុំស្រឡាញ់ត្រឹមមាត់ ត្រូវឧបត្ថម្ភជាតិនឹងអក្សរ-
សាស្ត្រ ដូចឧបត្ថម្ភកូន ទើបជាតិនឹងអក្សរសាស្ត្រ
រស់នៅដោយមានដីខ្មែរ ស្មើមុខនឹងអរិយប្រទេស
ក្នុងលោក ។

ឃ. អ.

# សត្ថា ទេវមនុស្សានំ

## ព្រះឧបាលិវង្ស ម៉ុង-សែស វត្តមហាមន្ត្រី

រៀបរៀង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងអរិយសង្ឃ ដោយសេចក្ដីគោរព) ។

ឱកាសនេះ អាត្មាភាពសូមសំដែងអំពីព្រះពុទ្ធគុណត្រង់បទថា សត្ថា ទេវមនុស្សានំ ដែលពុទ្ធបរិស័ទទាំងឡាយ ធ្លាប់សូត្រពោលថ្វាយបង្គំសព្វទិវារាត្រី ។ ពាក្យថា សត្ថា ទេវមនុស្សានំ នោះប្រែថា " ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ " គឺព្រះអង្គប្រៀនប្រដៅណែនាំពន្យល់ទេវតានិងមនុស្សឲ្យបានដឹងស្គាល់ច្បាស់ត្រង់ប្រយោជន៍ ៣ យ៉ាង គឺ ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ដែលកើតមានឡើងក្នុងបច្ចុប្បន្ននេះ ១ សម្បរាយិកត្ថៈ ប្រយោជន៍ដែលកើតមានឡើងក្នុងបរលោក ១ បរមត្ថៈ ប្រយោជន៍ដ៏សំខាន់ជាងគេបំផុតគឺព្រះនិព្វាន ១ ។

## ប្រយោជន៍ក្នុងបច្ចុប្បន្ន

៦ ប្រយោជន៍ដែលកើតមានឡើងក្នុងបច្ចុប្បន្ននេះ នោះសម្រេចមក

អំពីសេចក្តីព្យាយាមខំប្រឹងប្រែងរៀនចំណេះវិជ្ជា   តាំងអំពីអក្សរសាស្ត្រ លេខនព្វន្ត   រហូតដល់ទៅវិជ្ជាតូចធំផ្សេងៗ   មានវិជ្ជារបស់ជាងមាស ជាងប្រាក់   ជាងស្មិទ្ធិ   ជាងឥដ្ឋ   កំបោរ   ជាងឈើជាដើមក៏មាន, សម្រេចមកអំពីកម្លាំងកាយ   កម្លាំងចិត្ត   ខំខ្នះខ្នែងប្រឹងប្រែងធ្វើការងារ ឥតមានរអាទុញទ្រាំទ្រនឹងត្រជាក់ក្តៅ   នឿយហត់អត់ឃ្លានលំបាកក៏មាន, តាំងអំពីក្ររហូតដល់គ្រាន់ឡើង, សមដូចបទបាលិពុទ្ធភាសិតក្នុងមង្គល-សូត្រ ១ កន្លែងថា   អនាកុលា ច កម្មន្តា   ប្រែថា " ការងារមិនល្អក់   មិនផ្តេសផ្តាស   មិនវឹញ្ញា "   គឺ ការងារដែលត្រឹមត្រូវម៉ត់ចត់ស្អាតបាត;   ការងារបែបនេះជាមង្គលដ៏ឧត្តម   ។

ពាក្យថា " ការងារមិនល្អក់   មិនផ្តេសផ្តាស   មិនវឹញ្ញា "   នោះ សំដៅយកកសិកម្ម   គោរក្ខកម្ម   និងវាណិជ្ជកម្មជាដើម   ។

កសិកម្ម   គឺការងារភ្ជួររាស់ដីចំការឬស្រែ   ព្រមទាំងសាបព្រោះ ដកស្ទូង   ច្រូតបូតក្តិចកាប់   បោកបែនអុំពោយ   វែកពុនដឹកជញ្ជូនផល ស្រូវយកទៅដាក់ជោក   ដាក់ជង្រុក   ។

គោរក្ខកម្ម   គឺការងាររក្សាថែទាំគោក្របី   ដោយមេត្តាករុណាពិតៗ ខំប្រឹងប្រែងការពារចោរខ្មួយកុំឲ្យលួចប្លន់យកបាន   ការពារសត្វជាសត្រូវផ្សេងៗ   មានមូសស្លុចរបោមជាដើម   ប្រឹងប្រែងបំប៉នសោ្ហឲ្យធាត់ធំមានកម្លាំងច្រើន   ដើម្បីពឹងផ្អែកយកកម្លាំងសត្វទាំងនោះ   ជំនួសកម្លាំង

ខ្លួនផង ដើម្បីយកគោរសទាំង ៥ សម្រាប់ចិញ្ចឹមជីវិតខ្លួនផង លក់ដូរយកថ្លៃជាស្បៀងលៀងជីវិតទៅមុខផង ។

ឯគោរសទាំង ៥ នោះគឺៈ ខីរំ ទឹកដោះស្រស់ ១ ទធិ ទឹកដោះជូរបន្ទាប់អំពីទឹកដោះស្រស់នោះ ១ ឃតំ ទឹកដោះថ្លា ១ តក្កំ ទឹកដោះការគេលាយដោយទឹកសុទ្ធ ៣ ភាគ ទឹកដោះមួយភាគ តែមានរសជូរ ១ នវនីតំ ទឹកដោះខាប់ ១ ។

វណិជ្ជកម្ម គឺការដើរជួញប្រែតាមផ្លូវគោក ផ្លូវទឹក ក្នុងទីផ្ទះសំបែងកន្លែងកនផ្សារជាដើមផង ទិញថោកលក់ថ្លៃដោយមិនបំបាត់ប្រវញ្ចន៍ជាកំរៃចិញ្ចឹមជីវិត បង្កបង្កើនធនធានតាំងអំពីតិចតួច រហូតដល់ច្រើនរាប់មិនអស់, ដូចជាចូឡកន្តេវាសិកបុរស ក្នុងក្រុងពារាណសីក្នុងអតីតកាល កាលពីដើមនៅជាអ្នកបំរើរបស់ចូឡកសេដ្ឋី ជាអ្នកកំសត់ទ័ទ័លក្រ បានសត្វកណ្ដុរងាប់ត្រឹមតែមួយប៉ុណ្ណោះ យកទៅលក់ឲ្យគេ អ្នកចិញ្ចឹមឆ្មាម្នាក់ គេទិញយកទៅឲ្យឆ្មាស៊ី បានដំឡៃជាប្រាក់ចំនួន ១ កាកណិក យកប្រាក់ ១ កាកណិកនោះទៅទិញ របស់របរលក់ដូរតតេះតតោះយកចំណេញបន្តិចម្តងៗ យូរៗទៅ កាន់តែបានចំណេញច្រើនឡើងឥតអាក់ រហូតដល់ទៅមានប្រាក់ចំនួនពីរសែន (២០០.០០០) កហាបណៈ បុរសកំសត់នោះប្រកបដោយសេចក្ដីកតញ្ញូដឹងគុណឧបការចូឡក-

សេដ្ឋី ដែលបានសង្គ្រោះទំនុកបំរុងខ្លួនពីដើម ក៏យកប្រាក់ ១ សែន (១០០.០០០) កហាបណៈទៅជូនចូឡកសេដ្ឋីៗ ក៏គិតថាបុរសនេះ មិនមែនជាអ្នកថយថោកឡើយ ជាអ្នកប្រកបដោយបញ្ញាស្មារតី នឹងសេចក្តីព្យាយាមខ្មីឃ្មាត ឧហាតសង្វាតរកស៊ីធ្វើការជួញប្រែ ផ្សែផ្សំ សន្សំទ្រព្យសម្បត្តិបានច្រើនដល់ប៉ុណ្ណោះ បុរសនេះមិនសមនឹងនៅជាអ្នកបំរើអញទៀតឡើយ ហើយក៏ឲ្យកូនស្រីរបស់ខ្លួន ធ្វើជាភរិយារបស់បុរសនោះ ៗ លុះចូឡកសេដ្ឋីធ្វើមរណកាលទៅ បុរសនោះក៏បានឡើងជាសេដ្ឋីតំណាងចូឡកសេដ្ឋីនោះឡើង បានចំរើនរុងរឿងក្នុងបច្ចុប្បន្ន ជាតបដល់អស់ជីវិត ៗ

ម្យ៉ាងទៀត មនុស្សដែលខ្ជិលច្រអូស ដំអក់ទំរន់ពុតត្បុតច្រើនមិនប្រឹងប្រែងធ្វើការរកស៊ី រមែងជួបប្រទះនឹងទុក្ខលំបាក ដោយក្រខ្សត់អត់ឃ្លាន, សមដោយបាលីពុទ្ធភាសិត ១ កន្លែងថា:

អតិសីតំ អតិឧណ្ហំ អតិសាយមិទំ អហុ
ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា អច្ចេន្តិ មាណវេ

ប្រែថា "មនុស្សណានិយាយពាក្យត្អូញត្អែរបណ្តោះបណ្តៃថា ""ត្រជាក់ពេកណាស់ ក្តៅពេកណាស់ ល្ងាចពេកណាស់ ធ្វើការមិនបានទេ" ហើយមិនធ្វើការងារ, ប្រយោជន៍ទាំងឡាយគឺទ្រព្យសម្បត្តិ រមែង

លោកផ្តាំលែងមនុស្សនោះដែលលះបង់ការងារចោលចេញ មិនបិតទៅជិតមនុស្សនោះឡើយ" ។

មនុស្សដែលមានខន្តីអំណត់អត់ទ្រាំខំធ្វើការងារ រមែងបានសេចក្តីសុខ-ចំរើនជាខាងក្រោយ, សមដោយបាលីថា:

យោ ច សីតញ្ច ឧណ្ហញ្ច តិណា ភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ សោ សុខា ន វិហាយតិ

ប្រែថា "មនុស្សណាមិនសំគាល់នូវត្រជាក់និងក្តៅដោយក្រៃលែងជាងស្មៅ គឺជាមិនអើពើ មិនរអាធុញទ្រាន់នឹងត្រជាក់ក្តៅ សំគាល់ត្រជាក់ក្តៅនោះ ប្រហែលគ្នានឹងស្មៅដែលគេជាន់ដោយជើង, ខំប្រឹងប្រែងធ្វើកិច្ចការងាររបស់បុរស, មនុស្សនោះមិនសាបសូន្យចាកសេចក្តីសុខដែលកើតអំពីទ្រព្យសម្បត្តិ ព្រោះការចាយវាយទ្រព្យសម្បត្តិបរិភោគឡើយ" ។

ន័យមួយទៀត ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ បើប្រមូលរួបរួមទៅ មាន ៤ ប្រការ គឺ:

១.— ឧដ្ឋានសម្បទា ការក្រោកឡើងប្រញាប់ប្រញាល់រួតរះខ្នះខ្នែងស្វែងរកប្រយោជន៍ គឺទ្រព្យសម្បត្តិដោយពេញកម្លាំង ត្រាតែបានសម្រេចប្រយោជន៍ម្យ៉ាងៗ ដូចបានសំដែងហើយខាងដើម ។

២.— អារក្ខសម្បទា មានទ្រព្យសម្បត្តិមកហើយប្រឹងប្រែយ័ត្នរក្សាការពារថែទាំទ្រព្យសម្បត្តិនោះឲ្យគង់នៅមិនឲ្យរលាត់រទាំង មិនឲ្យអន្តរាយខូចខាតទៅដោយសត្រូវភ្លើង ចោរលួចជាដើម ។

៣.— កល្យាណមិត្តតា ការសេពគប់គប់ប្រុសផង និងអ្នកប្រាជ្ញសប្បុរសដែលមានសទ្ធាទៀងធ្វើជាមិត្តស្និទ្ធស្នាល ដេកអង្គុយឈរដើរជាមួយគ្នា ដើម្បីបើកភ្នែកពន្លឺកបញ្ញាឲ្យចេះដឹងស្គាល់ការខុសត្រូវ សត្វអន្ទើតែងបានល្អរុងរឿងដូចជាកជហាង្ស ដែលទំសម្ងំនៅលើកំពូលភ្នំមាស ដែលមានពន្លឺស្រស់ល្អ រាជហង្សក៏ល្អដោយសារភ្នំមាសនោះដែរ ។

៤.— សមជីវិតា ការចិញ្ចឹមជីវិតស្មើល្មមដោយទ្រព្យដែលខ្លួនរកបាន គឺរកមានតិចចាយរាយចិញ្ចឹមជីវិតតាមតិច រកបានច្រើនចាយរាយចិញ្ចឹមជីវិតតាមច្រើន មិនប្រើប្រាស់ឲ្យហួសហេតុហួសប្រមាណ មិនឲ្យជំពាក់បំណុលគេ ។

## ប្រយោជន៍ក្នុងបរលោក

ប្រយោជន៍ដែលកើតមានឡើងក្នុងបរលោកនោះ មានច្រើនប្រការណាស់ តែបើប្រមូលប្រួមឲ្យខ្លីទៅ មានត្រឹម ៤ ប្រការ គឺ:

១.— សទ្ធា ការជឿជាក់ចំពោះកម្មនិងវិបាកថា មានពិតមែន

អំពើល្អអាក្រក់ដែលធ្វើដោយកាយវាចាចិត្ត ហៅថា កុសលកម្ម អកុសលកម្ម, ផលដែលកើតចេញមកអំពីកម្មទាំងពីរនោះហៅថា វិបាក១ ជាអព្យាកតធម៌ មានប្រភេទច្រើន មានបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្តជាដើម ព្រមទាំងសុខទុក្ខ ដែលហៅថា វិបាកសុខ វិបាកទុក្ខ ។

មួយទៀត ការជឿថាសត្វមានកម្មជារបស់ខ្លួន សត្វធ្វើនូវកម្មណា ៗ ល្អឬអាក្រក់ តែងបានទទួលយកផលរបស់កម្មនោះ ៗ ។

ការជឿជាក់ចំពោះពោធិញ្ញាណរបស់ព្រះតថាគត សេចក្តីថា មានបុរសអស្ចារ្យខ្លះ ៗ បានបំពេញពុទ្ធការកធម៌ ឬបារមីធម៌ទាំង ១០ មានទានជាដើម បានពេញគ្រប់គ្រាន់ហើយ បានត្រាស់ដឹងធម៌ទាំងឡាយជាព្រះពុទ្ធប្រកបដោយគុណច្រើនប្រការ មានអស់កិលេសជាដើម ។ ការជឿដូច្នេះនាំឲ្យកើតកុសលទាំងពួង កើតផលល្អក្នុងលោកខាងមុខ បានជាហៅថា ប្រយោជន៍ក្នុងបរលោក ។

ម្យ៉ាងទៀត សទ្ធានេះជាគូគាប់នឹងបញ្ញា តែងជួយគាំពារយឹតយោងបញ្ញា ឲ្យស្ទុះឡើងទៅរកបុណ្យកុសលមិនឲ្យគ្រាន់តែដឹងទទេ ៗ ឥតមានធ្វើកុសលអ្វីសោះនោះឡើយ ។ សទ្ធានេះជាទ្រព្យប្រសើរវិសេសរបស់បុរសក្នុងលោកនេះ ហៅថាអរិយទ្រព្យផង ជាមិត្រសំឡាញ់របស់អ្នកដែលសាងបុណ្យកុសលទាំងពួងផង ។

២–សីល: ការសង្រួមប្រុងប្រយ័ត្នកាយវាចាឲ្យរៀបរយល្អ ឲ្យមានបែបបទសណ្ដាប់ធ្នាប់ត្រឹមត្រូវ, មានលក្ខណៈប្រមូលទុកនូវកាយកម្មវចីកម្ម មនោកម្ម ឲ្យមូលល្អ មិនឲ្យរាត់រាយខ្ចាត់ខ្ចាយផ្ដេសផ្ដាស, មានលក្ខណៈស្ពួយទ្រទ្រង់នូវកុសលធម៌ទាំងពួង ដូចជាផែនដីតែងស្ពួយទ្រទ្រង់នូវផ្ទះសំបែងព្រឹក្សាលតាវល្លិ៍ស្មៅជាដើម, មានប្រភេទច្រើន មានសីល ៥ សីល ៨ ជាដើម, សីលនេះបើបរិសុទ្ធបរិបូណ៌ពេញទីហើយ រមែងមានក្លិនក្រអូបក្រអែបក្រអូបឈ្ងុយឈ្ងប់ ផ្សាយទៅក្នុងមនុស្សលោកនិងទេវលោកជាហេតុនាំឲ្យបាននូវសុគតិភព, បានជាឈ្មោះថាប្រយោជន៍ក្នុងបរលោក ។

ម្យ៉ាងទៀតសីលនេះជាហេតុនាំឲ្យកើតសមាធិផង ជាទ្រព្យប្រសើរវិសេស ហៅថាអរិយទ្រព្យផង ជាបារមីផង ។

៣–ចាគៈ ការលះកាត់កាត់សេចក្ដីលោភ សេចក្ដីកំណាញ់ជាមន្ទិលចោលចេញ ហើយលើកយកទេយ្យវត្ថុ ឲ្យទានដល់អ្នកក្រីក្រលំបាកជាដើម, រមែងកើតផលល្អក្នុងលោកខាងមុខ ទើបបានឈ្មោះថាប្រយោជន៍ក្នុងបរលោក ។ ចាគៈនេះជាទ្រព្យប្រសើរវិសេសហៅថាអរិយទ្រព្យផង ។

៤–បញ្ញា សេចក្ដីដឹងទូទៅ ស្គាល់ច្បាស់ការខុសត្រូវបុណ្យបាបគុណទោសជាដើម ជាពន្លឺភ្លឺស្វាងរុងរឿងក្នុងលោកជាគ្រឿងទ្រោល

បំភ្លឺរបស់អ្នកដែលមានបញ្ញា, ជាគ្រូគ្នានឹងសត្វ តែងជួយគាំពារ ទំនុកបំរុងសត្វឲ្យដើរទៅតាមផ្លូវត្រង់ មិនឲ្យដើរខុសផ្ដេសផ្ដាសប្រទេសប្រទាស ឥតប្រយោជន៍, តែងជួយដុសខាត់សីល ឲ្យបរិសុទ្ធផូរផង់ឡើង ឬជួយអប់រំសីល ឲ្យក្រអូបឈ្ងុយឈ្ងប់ឡើង, តែងជួយចាគៈ ការបរិច្ចាគទានឲ្យមានផលច្រើនឡើង ជាកុសលមូល គឺជាហេតុនាំឲ្យកើតកុសលទាំងពួងដែលជាត្រៃហេតុ ទើបបានឈ្មោះថាប្រយោជន៍ក្នុងបរលោក ។ ជាទ្រព្យប្រសើរវិសេស ហៅថា បញ្ញាបារមីផង ។

បញ្ញានេះបានចំរើនមោះមុតស្រួចស្រាលឡើង ដោយហេតុបានសេពគប់នឹងអ្នកប្រាជ្ញសប្បុរស ដែលមានបញ្ញាជ្រាលជ្រៅមានចំណេះវិជ្ជាច្រើន ព្រមទាំងបានសិក្សារៀនសូត្រចំណេះវិជ្ជាមកពលជាតិពលកត, ប្រៀបដូចកាំបិត ដែលបានស្រួចស្រាលមុតថ្លាឡើង ក៏អាស្រ័យថ្មនឹងទឹកព្រមទាំងកម្លាំងព្យាយាមរបស់បុរសដែលប្រឹងប្រែងដុសខាត់ សំលៀងសង្កតបាប់មុខញយៗ ។

## ប្រយោជន៍ដ៏សំខាន់គឺព្រះនិព្វាន

៦ប្រយោជន៍ដ៏សំខាន់ជាងគេបំផុតគឺព្រះនិព្វាននោះ និព្វានៈ ជាពាក្យបាលី ប្រែកាត់បទជាពីរបទ និ បទ ១ ព្វានៈ បទ ១, និ ប្រែថាគ្មាន, ព្វានៈ ជាគួតណ្ហា ប្រែថា " ដោតក្រង - ដេរ - ចាក់ស្រែះរូបរឹត "; តបទទាំងពីរបូលគ្នាជា និព្វានៈ ប្រែថា " គ្មានតណ្ហា

ព្រះនិព្វានសម្រេចមកអំពី អដ្ឋង្គិកមគ្គ គឺផ្លូវមានអង្គ ៨ គឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ ១ សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវ ១ សម្មាវាចា និយាយត្រូវ ១ សម្មាកម្មន្តៈ ការងារត្រូវ ១ សម្មាសតិ សេចក្តីរឭកត្រូវ ១ សម្មាសមាធិ ការដំកល់ចិត្តត្រូវ ១ ត្រូវជា ៨ ។ មគ្គទាំង ៨ នេះ ហៅថា និព្វានគាមិនីបដិបទា សេចក្តីប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វាន។ នេះហៅថា បរមត្ថៈ ប្រយោជន៍ដ៏សំខាន់ជាងគេបំផុត ។

ព្រះដ៏មានព្រះភាគទ្រង់ទូន្មាន ប្រៀនប្រដៅទេវតានិងមនុស្សឲ្យស្គាល់ប្រយោជន៍ទាំង ៣ ដូចមានសំដែងមកហើយដោយសង្ខេបនេះ ទើបបានទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ។

អាត្មាភាពសំដែងធម៌មកនេះ ក៏សូមបញ្ចប់ធម៌ទេសនា ត្រឹមតែប៉ុណ្ណេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណា ជាអម្ចាស់ជីវិតព្រះចៅក្រុងកម្ពុជាធិបតី ប្រិយមហារាជ ព្រមទាំងព្រះរាជវង្សានុវង្ស សូមជូនកុសលដល់អស់លោកអ្នករាជការគ្រប់ដំណែងក្នុងកម្ពុជរដ្ឋ និងពួកអស់លោក - អ្នកសប្បុរសដែលបានស្តាប់ធម៌នេះ សូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផល ដូចប្រាថ្នាកុំបីឃ្លាតឡើយ ឯវំ សង្ខេបេន សម្មត្តា ធម៌ទេសនាក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

---

## ទុលកបណ្ឌិតទី ១១

លោកអាចារ្យ ឈឹម-ណាក ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

កម្មយោនិ កម្មពន្ធូតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទានបារមឹ អារព្ភ កថេសិ ។

សត្ថា កាលអង្គសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ទ្រង់ប្រថាប់នៅវត្តជេតពន នាក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវទានបារមីរបស់ព្រះអង្គ ទ្រង់សំដែងធម៌ទេសនាមានបទថា កម្មយោនិ កម្មពន្ធុ ដូច្នេះជាដើម ។

មានសេចក្តីដំណាលថា ក្នុងសម័យដែលកន្លងទៅហើយ កាលព្រះដ៏មានព្រះភាគជាលោកនាយកទ្រង់ព្រះនាមកស្សប បរិនិព្វានទៅបាន ៧ ថ្ងៃ មានព្រះរាជា ១ ព្រះអង្គ ទ្រង់ព្រះនាមចិន សោយរាជសម្បត្តិក្នុងចិនរដ្ឋ ។ នៅក្នុងនគរនោះ មានព្រាហ្មណ៍ម្នាក់ជាបុរោហិតរបស់

ព្រះអង្គ ៗ ក្នុងសម័យនោះមានភិក្ខុ ៣៣ រូប មានឥន្ទ្រិយស្រគត់ស្រគំរម្យទំ យ៉ាងនៃក្រៃលែង បាននិមន្តចូលមកតាមវិថីនៃនគរ ៗ ព្រាហ្មណ៍បុរោហិត បានឃើញភិក្ខុទាំងនោះហើយគិតថា យីអើហ្ន៎ ! សមណៈទាំងនេះ ចូលមកក្នុងនគរ បើព្រះរាជា ជាម្ចាស់អញបានឃើញ ប្រាកដជាទឹងមានព្រះរាជហឫទ័យជ្រះថ្លា ចំពោះពួកស្រមណ៍ទាំងនេះមិនខាន កាលបើជ្រះថ្លាយ៉ាងនេះហើយ, លាភសក្ការៈរបស់អញទឹងសាបសូន្យជាប្រាកដ; បើដូច្នោះមានតែអញបំបែកលទ្ធិរបស់ព្រះរាជាទឹងញុំាងព្រះអង្គឲ្យសម្លាប់ពួកស្រមណ៍ទាំងនេះពេលទើបគួរ ៗ គ្រានោះ ព្រាហ្មណ៍បុរោហិត ក៏ប្រញាប់ប្រញាល់ដម្រង់ទៅកាន់សំណាក់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ចាប់ព្រះហស្តព្រះរាជានាំទៅខាងលើប្រាសាទ ក្រាបបង្គំទូលថា បពិត្រមហារាជ, ពួកចោរទាំងនោះ ក្លែងភេទជាភិក្ខុ មានប្រាថ្នាទឹងផ្ទួនអ្នកនគរទាំងអស់ ៗ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញពួកភិក្ខុទាំងនុ៎ះហើយទ្រង់ត្រាស់ថា បពិត្រលោកអាចារ្យ, ជនទាំងនេះឈ្មោះថាភិក្ខុជាសាវ័កព្រះមហាសមណៈទេតើ ៗ ព្រាហ្មណ៍បានឮព្រះរាជាមានព្រះរាជតម្រាស់ដូច្នោះហើយ ក៏ក្រាបបង្គំទូលម្តងទៀតថា បពិត្រព្រះសម្មតិទេព, នេះប្រាកដជាពួកចោរក្លែងភេទជាភិក្ខុ មានបំណងទឹងចូលមកផ្ទួនអ្នកនគរទាំងអស់មែន ព្រះអង្គ! ៗ ព្រះរាជាទ្រង់ព្រះសវនាការស្ដាប់ពាក្យព្រាហ្មណ៍នោះ ក៏ទ្រង់ជឿពាក្យព្រាហ្មណ៍ជាបាបមិត្ត ហើយ

ត្រាស់ថា អើលោកអាចារ្យ, បើដូច្នោះតើយើងនឹងធ្វើដូចម្តេច ៗ ព្រាហ្មណ៍បុរោហិតក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, សូមព្រះអង្គកុំបង្អែបង្អង់ឡើយ, សូមឲ្យរាជបុរសចាប់ពួកភិក្ខុទាំងនោះចង ហើយឲ្យវាយយ៉ាងខ្លាំង នាំយកទៅដោតលើឈើអណ្តាត ៗ ព្រះរាជាទ្រង់ព្រះសវនាការពាក្យព្រាហ្មណ៍បុរោហិតនោះហើយ ទ្រង់មានព្រះរាជឱង្ការថា "ស្រួលហើយលោកអាចារ្យ" រួចទ្រង់ត្រាស់ហៅពួកពេជ្ឈឃាតឲ្យចូលមកយ៉ាងរួសរាន់ ទ្រង់ត្រាស់ព្រះរាជបញ្ជាថា នែវ៉ើយ ! ពួកពេជ្ឈឃាត, ចូរឯងរាល់គ្នាទៅចាប់ពួកចោរក្នុងភេទជាភិក្ខុ ចងវាយសំពងកុំត្រាប្រណីឡើយ, ហើយនាំទៅឯព្រៃស្មសាន ដោតលើចុងឈើអណ្តាតទៅ ៗ

លំដាប់នោះ ពួកពេជ្ឈឃាតដែលជាមនុស្សគ្មានសេចក្តីអាណិតអាសូរ ជាមនុស្សគ្មានដឹងគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ បានស្តាប់ព្រះរាជឱង្ការហើយក៏ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ប្រពៃហើយ ៗ ពួកពេជ្ឈឃាតទាំងនោះ ក៏នាំគ្នាទៅកាន់សំណាក់ព្រះនាគឧបគុត្ត ហើយទាញយកបាត្រមកបំបែកចោល, ពួកពេជ្ឈឃាតខ្លះចាប់យកចីវរមកហែកចោល, ពួកពេជ្ឈឃាតខ្លះវាយសំពងព្រះសិរលោកទាំងនោះ, ពួកពេជ្ឈឃាតខ្លះវាយទះមាត់ ៗ គ្រានោះ ភិក្ខុទាំងឡាយបានសេចក្តីទុក្ខលំបាកយ៉ាងសំបើម; មានឈាមហូរចេញពីត្រចៀក ច្រមុះ មាត់ គ្រប់ៗរូប ៗ ភិក្ខុទាំងនោះ ក៏ស្រែកទ្រហោយំប្រមះនទៀល រងទុក្ខវេទនាជាយ៉ាង

ក្រៃលែង ៗ លំដាប់នោះ ព្រះសង្ឃត្ថេរលួងលោមភិក្ខុទាំងនោះហើយ លោកសំដែងប្រាប់ឲ្យដឹងខ្លួនដោយធម្មកថាថា "ម្នាលលោកដ៏មានអាយុទាំងឡាយ, លោកកុំគិតឡើយ, លោកកុំសោយសោកឡើយ, នេះហើយជាទោសរបស់កម្មចាស់នៃយើងរាល់គ្នា;. លោកទាំងអស់មិនដឹងទេឬ? រឿងនេះព្រះពុទ្ធដ៏មានបុញ្ញរាសី ទ្រង់បានត្រាស់សំដែងរួចហើយតើ;" ហើយលោកពោលពុទ្ធគាថាប្រាប់ភិក្ខុទាំងឡាយថា:

កម្មយោនី កម្មពន្ធូ  កម្មស្សកា ភវាភវេ
យាវ កម្មា ន មុញ្ចន្តិ  តាវ កម្មេន សំសរា
កម្មស្សកា កម្មទាយាទា  កម្មប្បដិសរណា តេ
យំ យំ កម្មំ អកំសុ ប  តំ តន្នេសំ ផលំ ទទេ

សត្វទាំងឡាយ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជារបស់ខ្លួន; សត្វទាំងឡាយមិនអាចរួចចាកកម្មដកបណា ក៏តែងជាប់ជំពាក់ដោយកម្មដកបនោះ ក្នុងភពតូចភពធំ, សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាគ្រឿងប្រគល់ឲ្យនូវផល មានកម្មជាទីពំនាក់អាស្រ័យ; សត្វទាំងឡាយបានធ្វើហើយនូវកម្មឯណា កម្មនោះរមែងប្រគល់ឲ្យនូវផលដល់សត្វទាំងឡាយនោះ ៗ

គ្រានោះ ពួកអ្នកនគរទាំងអស់ក៏ផ្អើលឆោឡោឡើង ៗ កាលណោះ ព្រះពោធិសត្វនៃយើង ទ្រង់ព្រះនាមទុលកបណ្ឌិត កើតក្នុងត្រកូលសេដ្ឋី បានជ្រាបព័ត៌មាននោះហើយ ក៏មកប្រញាប់ប្រញាល់ ចូលទៅរកព្រះនាគទីបកត្ថេរ, លុះចូលទៅដល់សំណាក់លោកក៏ក្រាបថ្វាយបង្គំព្រះថេរៈ ហើយសួរថា បពិត្រលោកម្ចាស់, លោកម្ចាស់រាល់អង្គ មានទោសកំហុសដូចម្តេច? ៗ លំដាប់នោះ ព្រះថេរៈមានថេរវាចាថា ក្នុងអត្តភាពនេះ ទោសរបស់អាត្មាភាពទាំងអស់ មិនប្រាកដឡើយ, បើក្នុងកាលអតីតកត អាត្មាភាពទាំងអស់ មិនអាចនឹងដឹងទោសដែលកើតឡើងបានឡើយ ៗ លំដាប់នោះ ព្រះពោធិសត្វដោះគ្រឿងអម្ពរឲ្យដល់ពួកពេជ្ឈឃាត ហើយប្រាប់ថា អ្នកទាំងឡាយ ចូរបង្អង់បន្តិចសិនដោយសេចក្តីសង្គ្រោះដល់ខ្ញុំ ៗ ក្សណនោះ ព្រះពោធិសត្វទៅកាន់ព្រះរាជដំណាក់ ថ្វាយបង្គំព្រះរាជា ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេពវង្សដ៏ទ្រង់នូវព្រះរាជ-សម្ភារ, សូមទ្រង់ព្រះមេត្តាប្រោសសង្គ្រោះទូលព្រះបង្គំជាខ្ញុំ ៗ នឹងសូមថ្វាយមាសប្តូរប្រាក់តាមសព្វព្រះរាជហឫទ័យ ដើម្បីទិញយកកក្កុទាំង ៣៣ រូប ដែលព្រះករុណាជាម្ចាស់ជីវិតឲ្យពួកពេជ្ឈឃាតយកទៅសម្លាប់ ៗ ព្រះរាជាទ្រង់ព្រះសវនាការពាក្យព្រះពោធិសត្វហើយ ទ្រង់មានព្រះរាជ-ឱង្ការថា ហៃទុលកបណ្ឌិត, ពិតប្រាកដដូចជាអ្នកនិយាយមែនឬអ្វី? ៗ ព្រះពោធិសត្វក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស! ពិតប្រាកដ

ដូចបានក្រាបបង្គំទូលមែន ៗ ព្រះកដាទ្រង់ត្រាស់ថា អើទុលកបណ្ឌិត! បើដូច្នោះ ចូរឯងឲ្យមាសចំនួនទម្ងន់ប៉ុនគ្នានឹងទម្ងន់សរីរៈកុមារទាំងនុ៎ះមកយើងចុះ ។ ទុលកបណ្ឌិត បានស្ដាប់ព្រះរាជឱង្ការនោះហើយ ក៏មានហឫទ័យពេញដោយបីតិសោមនស្ស ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ប្រពៃណាស់ព្រះអង្គ! ហើយក្រោកចេញពីអាសនៈទៅផ្ទះ ប្រញាប់ប្រញាល់ ក្រាបថ្វាយបង្គំមាតាហើយជម្រាបតាមសេចក្ដីពិតថា បពិត្រមាតា, ខ្ញុំបាទសូមមាស, សូមមាតាឲ្យមាសដល់កូនកុំខាន ៗ មាតាបានស្ដាប់ពាក្យព្រះពោធិសត្វហើយសួរថា ម្នាលកូនជាទីពេញចិត្តម្ដាយ! អ្នកយកមាសធ្វើអ្វី? ។ ពោធិសត្វជម្រាបថា បពិត្រមាតា, ខ្ញុំបាទយកទៅលោះកុមារទាំង៣ រូប ដែលស្ដេចឲ្យចាប់យកទៅសម្លាប់ ។ មាតាអង្អែលពោះខ្លួនហើយលាន់មាត់ថា "ឱហ្ន! អញបានកូននេះមកប្រកបដោយផលល្អណាស់តើ!" ហើយនិយាយថា ហៃកូនជាទីស្រឡាញ់ពេញចិត្តមាតា, ចូរអ្នកយកមាសតាមគាប់ចិត្តចុះ ។ ព្រះពោធិសត្វបានស្ដាប់ពាក្យមាតាហើយ ក៏មានហឫទ័យពេញដោយបីតិ ក្រោកចាកអាសនៈស្លៀកសំពត់មានដម្លៃកាត់មិនបាន ចូលទៅកាន់ឃ្លាំងមាសដូចជាមណ្ឌលនៃព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី មានរស្មីក្ដីត្រចះអណ្ដែតត្រសែតទៅក្នុងកណ្ដាលនភាល័យដូច្នោះ ហើយដឹកនាំយកមាសទៅគរជាគំនរក្នុងព្រះរាជលាន ទើបចូលទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រ

ព្រះសម្មតិទេព ,  កាលនេះជាកាលគួរហើយ  សូមព្រះអង្គទទួលយកមាសដែលទូលព្រះបង្គំជាខ្ញុំយកមកគរថ្វាយក្នុងទីនេះ  តាមសព្វព្រះរាជហឫទ័យ ។ ព្រះរាជាទ្រង់ព្រះសវនាការពាក្យពោធិសត្វហើយ  ទ្រង់មានព្រះរាជឱង្ការថា  អើបើដូច្នោះ  ចូរអ្នកឯងឲ្យមកចុះ ។ លំដាប់នោះ  ទុលកបណ្ឌិតចូលទៅកាន់សំណាក់ព្រះនាគទីបេកោត្រ  ហើយក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន  និយាយថា  បពិត្រលោកម្ចាស់ដ៏ចំរើន,  សូមលោកម្ចាស់ជួយសង្គ្រោះដល់ខ្ញុំព្រះករុណា,  សូមឡើងគង់លើជញ្ជីង,  ខ្ញុំព្រះករុណានឹងដាក់មាសទម្ងន់ប៉ុនសរីរៈលោកម្ចាស់  ហើយនឹងឲ្យជាថ្លៃនៃលោកម្ចាស់  ព្រះពោធិសត្វមានប្រាថ្នានឹងដោះភិក្ខុទាំង ៣ ៣ រូបតាមទំនងនេះ  ហើយពោលប្រកាសដល់ទេវតាទាំងឡាយថា

សុណន្តុ ភោន្តោ មេ វចនំ ទេវសង្ឃា  សមាគតា
ភិក្ខុំ ហិ បមោចេយ្យំ  ពោធិយាយេវ ការណា

បពិត្រទេវតាទាំងឡាយដ៏ចំរើន,  សូមពួកទេវតាទាំងអស់
ក្នុងលោធាតុ ... 

លំដាប់នោះពោធិសត្វ  បានញុំាំងពួកទេវតាឲ្យដឹងដូច្នោះហើយ ក៏ដោះលែងភិក្ខុទាំង ៣៣ រូប, ប៉ុន្តែនៅសល់ភិក្ខុ ៣ រូបក៏អស់មាសទៅ ។ ព្រះរាជាឃើញដូច្នោះហើយ ទ្រង់មានព្រះរាជឱង្ការថា នែកុលកបណ្ឌិត, អ្នកមានមាសទៀតដែរឬ? ។ ពោធិសត្វក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំអស់មាសហើយ ។– អើកុលកបណ្ឌិត, បើដូច្នោះអ្នកឯងគិតដូចម្តេច? ។ ពោធិសត្វបានស្តាប់ពាក្យនោះហើយក្រាបបង្គំទូលថា “សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គបង្អង់បន្តិចសិន” ហើយក្រាបថ្វាយបង្គំព្រះរាជាក្រោកចាកអាសនៈទៅកាន់ផ្ទះអាត្មា ប្រាប់ភរិយាថា ម្នាលប្អូនស្រី, បងសូមលានាងហើយ ដ្បិតបងបានយកមាសទៅថ្វាយស្តេច ដើម្បីដោះលែងពួកភិក្ខុ ៣៣ រូប ដែលស្តេចចាប់ពន្ធ, ឥឡូវមាសអស់ទៅ នៅសល់ភិក្ខុ ៣ រូប, បងនឹងលក់ខ្លួនបងឲ្យតែបានទ្រព្យយកមកបំពេញទានបារមី ។ ភរិយាបានឮពាក្យស្វាមីប្រាប់ ក៏ឆ្លើយឡើងថា បពិត្រអ្នកម្ចាស់ជាអយ្យបុត្រ, សូមអ្នកកុំលក់ខ្លួនអ្នកឡើយ, សូមលក់ខ្ញុំព្រមទាំងកូនឲ្យទៅនៅជាទាសីអ្នកដទៃវិញចុះ, អ្នកត្រូវការយកថ្លៃប៉ុន្មាន តាមសេចក្តីគាប់ចិត្តចុះ ។ ព្រះពោធិសត្វបានឮភរិយាថាដូច្នោះ ក៏កើតបីតិសោមនស្សពេញហឫទ័យ ស្រដីថា ម្នាលប្អូនស្រី, ស្រួលណាស់ហើយ ។ ចាប់ដៃភរិយាដើរទៅរកអ្នកមានទ្រព្យ ដល់ហើយនិយាយថា អ្នកយកកូនប្រពន្ធខ្ញុំនេះចុះ ហើយសូមអ្នកឲ្យមាសមកខ្ញុំ ។ នឹងយកទៅលោះភិក្ខុពីររូបដោយថ្លៃអ្នកទាំងពីរនេះ ។ លំដាប់

នោះមានសាមណេរតូច ១ រូបនៅសល់ មាសក៏អស់ទៅ ៗ សាមណេរនោះ មានសេចក្ដីកិតភ័យអំពីសេចក្ដីស្លាប់ យំសោកស្ដាយខ្លួនឱនព្រះសិរ មានមុខជោកជាំដោយទឹកភ្នែក ស្រែកទ្រហោយំ ហើយនិយាយនឹងពួកពេជ្ឈឃាតថា ម្នាលអ្នកពេជ្ឈឃាត, ចូរអ្នកជោតអាត្មាដោយដែកស្រួចនេះឲ្យស្លាប់ឆាប់ៗទៅចុះ ៗ លំដាប់នោះ ពួកពេជ្ឈឃាតទាំងអស់ បានស្ដាប់ពាក្យសាមណេរដែលឥតទីពឹងដូច្នោះ ក៏បែរជាដោះលែងបណ្ដោះអាសន្នសិន ៗ សាមណេរបានឱកាសដូច្នោះហើយក្រោកដើរតម្រង់ទៅកាន់សំណាក់ព្រះនាគទីបកត្ថេរ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានទូលថា បពិត្រលោកម្ចាស់ដ៏ចំរើន, ខ្ញុំព្រះករុណា សូមថ្វាយបង្គំលាលោកម្ចាស់ហើយ, សូមលោកម្ចាស់មេត្តាសង្គ្រោះខ្ញុំព្រះករុណា ? តាំងពីខ្ញុំព្រះករុណាបួសមក ក្រែងជួនជាមានសេចក្ដីភ្លាំងភ្លាត់បន្តិចបន្តួច ជាកាយកម្ម វចីកម្ម មនោកម្ម សូមលោកម្ចាស់មេត្តាអត់ទោសគឺសេចក្ដីភ្លាំងភ្លាត់ទាំងអស់នោះដល់ខ្ញុំព្រះករុណា ; នេះជាទីបំផុតនៃអភិវន្ទនាការ របស់ខ្ញុំព្រះករុណាហើយ; បពិត្រលោកម្ចាស់ដ៏ចំរើន, បើមាតាបិតាខ្ញុំព្រះករុណាសួររក, សូមលោកម្ចាស់ប្រាប់ដំណឹងតាមរឿងរ៉ាវហ្នឹងផងចុះ, សូមលោកម្ចាស់ឲ្យវត្ថពន្ធបង្កេះ ចីវរ សាដកនេះដល់មាតាបិតាខ្ញុំព្រះករុណាឲ្យបានផង, មាតាបិតាខ្ញុំព្រះករុណានឹងស្គាល់នូវវត្ថុទាំងនេះបាន; ម្យ៉ាងទៀត គាត់នឹងបន្ទោបង់នូវសេចក្ដីសោកស្ដាយខ្ញុំ

ព្រះករុណាបាទ, សាមណេរបានពោលពាក្យដូច្នេះហើយ ក៏ស្ទើរនឹងបែកបេះដូងជាពីរភាគ ហើយអង្គុយទ្រហោយំក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈ ។ ព្រះនាគទីបកត្ថេរ បានស្ដាប់ពាក្យសាមណេរចរចាប្រាប់សព្វគ្រប់ហើយ មានព្រះទ័យញាប់ញ័ររន្ធត់ស្ទើរតែនឹងបាត់ស្មារតី ទើបលោកនិយាយថា ម្នាលសាមណេរ អ្នកកុំគិតឡើយ, កុំសោយសោកឡើយ, អាត្មាមិនលះបង់ជីវិតអ្នកឯងឡើយ ។ លោកលួងលោមសាមណេរហើយសំដែងធម៌ទេសនាថា

សព្វេ វិ អនិច្ចធម្មា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារទាំងអស់របស់សត្វទាំងឡាយ មានការមិនទៀង
ជាធម្មតា, មានការកើតឡើងនឹងរលត់ទៅវិញជាធម្មតា,
កើតឡើងហើយ រមែងរលត់ទៅវិញ. ការរម្ងាប់នូវសង្ខារ
ទាំងនោះ ជាគ្រឿងនាំមកនូវសេចក្ដីសុខ ។

ព្រះថេរៈប្រៀនប្រដៅសាមណេរនោះដោយធម្មកថាយ៉ាងនេះឯង ។ ទុលកបណ្ឌិតបានស្ដាប់ធម៌ទេសនារបស់ព្រះថេរៈនោះហើយ ក៏និយាយនឹងខ្លួនឯងថា នែទុលកបណ្ឌិត, អ្នកឯងស្រឡាញ់ជីវិតជាង ឬមួយស្រឡាញ់ព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាង? លុះនិយាយដូច្នោះហើយ ក៏ពោលបង្អាប់បន្ទុះខ្លួនឯង ហើយចូលទៅរកព្រះរាជាក្រាបបង្គំទូលថា: សូមទ្រង់

ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំនឹងលះបង់ជីវិតជំនួសសាមណេរ ។ ព្រះរាជាទ្រង់ព្រះសវនាការហើយ ទ្រង់មានព្រះរាជឱង្ការថា ម្នាលទុលក, ពិតមែនឬអី? ។ - សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ - អើបើពិតយ៉ាងហ្នឹងមែន, ចូរអ្នកឯងប្ដូរជីវិតចុះ ។ ពោធិសត្វ មានហឫទ័យប្រកបដោយបីតិសោមនស្ស ហើយក្រោកចាកអាសនៈទៅកាន់សំណាក់សាមណេរ ដោះលែងសាមណេរអំពីចំណង ហើយពោលប្រកាសទេវតាដោយសច្ចវាចានេះថា :

បពិត្រទេវតាក្នុងឆកាមាវចរសួគ៌ទាំងឡាយ, សូមលោកអញ្ជើញមកជួបជុំចាំស្ដាប់ពាក្យខ្ញុំ! ដ្បិតខ្ញុំបានលះបង់ជីវិតរបស់ខ្លួន ព្រោះហេតុបង់បានពោធិញ្ញាណតែម្យ៉ាង; ពួកទេវតាដែលឋិតនៅនាអាកាសក្ដី ឋិតនៅលើផែនដីក្ដី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្ដី អារក្ខទេវតាទាំងឡាយក្ដី សូមអនុមោទនាបុណ្យខ្ញុំ; ដោយការបរិច្ចាគជីវិតនេះ ខ្ញុំសូមឲ្យបានត្រាស់ជាព្រះពុទ្ធ ចំឡងមនុស្សនឹងទេវតា ទៅកាន់ត្រើយនៃជាតិក្នុងកាលជាអនាគត, ម្យ៉ាងវិញទៀត បើខ្ញុំនៅអន្ទោលក្នុងវដ្ដសង្សារ, សូមកុំឲ្យឃើញជនពាលទាំងឡាយនោះ, សូមឃើញតែពួកសប្បុរសដែលបដល់ព្រះនិព្វានជាឋានខ្ពង់ខ្ពស់បំផុត ។

ព្រះពោធិសត្វ ក៏ដោះសាមណេរលែងអំពីចំណង ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់រក្សាសីល ចំរើនមេត្តាភាវនា ផ្សាយសេចក្តីមេត្តាចំពោះសត្វទាំងឡាយ ហើយសូមគង់នៅជាសុខចុះ", ហើយក្រាបថ្វាយបង្គំសាមណេរដោយបញ្ចង្គប្រតិស្ឋាន ពោលយ៉ាងនេះថា "ប្រសិនជាខ្ញុំព្រះករុណា មានទោសគឺសេចក្តីធ្វេស-ប្រហែសឯណាទីមួយ ជាកាយកម្ម វចីកម្ម មនោកម្ម សូមលោកម្ចាស់អត់ទោសនោះ ៗ ដល់ខ្ញុំព្រះករុណា", ហើយក្រោកចាកអាសនៈ ទៅកាន់ពួកពេជ្ឈឃាត ប្រាប់ពួកពេជ្ឈឃាតថា ម្នាលពេជ្ឈឃាតដ៏ចំរើន, ចូរអ្នកចងខ្ញុំហើយកាប់ខ្ញុំតាមគាប់ចិត្តចុះ ។

លំដាប់នោះពួកពេជ្ឈឃាត ចាប់វុលកបណ្ឌិតចងដោយចំណងប្រាំប្រការ រិតត្រួតយ៉ាងមាំ វាយដំសំពងយ៉ាងខ្លាំង នាំយកទៅព្រៃស្ម-សានភ្លាម ៗ ក្នុងថ្ងៃនោះ ពួកអ្នកនគរទាំងអស់ ក៏ខ្ញុកខ្ញួកភ្ញាក់ផ្អើលឆោឡោឡើង ៗ លំដាប់នោះមាតាព្រះពោធិសត្វ បានជ្រាបព័ត៌មាននោះហើយ ក៏លើកដៃទាំងពីរគក់ទ្រូងគក់ស្មា រំសាយសក់ស្រែកទ្រហោយំ ខ្សឹកខ្សួលអួលអុក ចុះចាកគេហស្ថាន រត់ទៅតាមកូនឯព្រៃស្មសាន, លុះទៅដល់ឃើញកូនដែលពួកពេជ្ឈឃាតចងរឹតត្រួតជាប់ដោយចំណង ៥ ប្រការ ដែលគ្មានទោសកំហុសបុន្តិចបន្តួចសោះ ហាក់ដូចជាមានហឫទ័យនឹងបែកសញ្ញែកជាប្រាំពីរផ្នែក ស្រែកយំអង្វរកូនថា: (មានត)

# រឿងសៅរ៍សោយ

(សិរីសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្ពីរសាស្ត្រស្លឹករឹត

(តពីលេខ ១០)

---

ស៊ីស្រូវទើបវិលយាត្រា ទៅមើលគោណា ពុំឃើញវាសោះ ។
តាមពិតរីឯគោនោះ ពុំស៊ីស្មៅសោះ ពីព្រោះឃើញញី ។
ស្ទុះបោលពុំបានរកស៊ី ដាច់ខ្សែខ្ទេចខ្ទី តាមញីទៅបាត់ ។
ម្ចាស់គោដើររកប្រវាត់ តាមគោដែលបាត់ ពុំឃើញរឹងក្តៅ ។
ចួនជាបែរភ្នែកសំដៅ មើលចំពោះទៅ ខាងមុខនោះនៃ ។
ឃើញព្រះសិរីសៅរ៍ជៀស្តដ័យ ដឹកអាជានេយ្យ បណ្ដើរយាត្រា ។
ម្ចាស់គោសំគាល់សញ្ញា ថាគោអាត្មា ឥតមានសង្ស័យ ។
រួចរត់ប្រញាប់វៃៗ ដល់ហើយថាហៃ អាចោរចិត្តកាច ។
ហ៊ានលួចគោអញឥតខ្លាច យើ! អាកំណាច ចិត្តកាចអប្រិយ ។
កាលនោះក្សត្រថ្ងៃពិសី ស្ដេចស្ដាប់សំដី គេជេរឥតក្រែង ។
ស្ដេចបើកព្រះឱស្ឋថាថ្លែង ប្រាប់ថាខ្ញុំឯង មិនជាចោរឡើយ ។
សេះខ្ញុំបរមកយូរហើយ ឥឡូវម្ដេចឡើយ មកថាគោខ្លួន ។
អ្នកនេះមិនដឹងសមសួន ទ្រព្យគេទ្រព្យខ្លួន ឲ្យច្បាស់ជាក់លាក់ ។

ម្ចាស់គោទឹងណាស់លោធាក់ ហើយចាប់កន្ត្រាក់ ក៏យកពោធិសត្វ ។
ក៏យដំធាក់ប្រទះទាត់ ពន្យពោធិសត្វ ហើយក៏ដេរថា ។
អាគាចកំណាចឫស្យា ម្តេចឡើយក៏អា ហ៊ានក្លាដដែក ។
គោអញ ៗ ឃើញទឹងក្អែក ម្តេចមិនប្រកែក ក៏សរើកដូច្នេះ ។
អញមិនស្គាល់ឬអាផែះ គោហើយទឹងសេះ កាលណាដូចគ្នា ។
ពេលនោះពន្ធកព្ធា ឃើញសេះអាត្មា ក្លាយជាគោហើយ ។
ក្សត្រថ្លៃអាល័យឥតស្បើយ ថា ឱ ! អ្នកអើយ ! ចូរអ្នកយកទៅ ។
ខ្ញុំសូមតែបានរស់នៅ គោអ្នកយកទៅ ខ្ញុំឥតបើថា ។
ម្ចាស់គោឮព្រះក៏ថា ថាឲ្យគោណា បន្ទោទឹងបាត់ ។
ហើយយកព្រះទីនាំងរត្ន ឯអគ្គមហាក្សត្រ កើតទុក្ខខ្លាំងក្លា ។
ព្រោះទ្រង់មានចិត្តស្នេហា ស្រឡាញ់លើអា- ជានេយ្យនោះណាស់ ។
កាលសេះនោះព្រាត់ស្រឡះ ទើបធ្វើឲ្យព្រះ- អគ្គស្តាយពេកក្រៃ ។
នេះឯងជាកម្មចង្រៃ នៃព្រះជៀស្តជ័យ តាមទាន់ឲ្យផល ។
ហេតុនោះទើបព្រះទសពល ទេសនាពន្យល់ ដល់សត្វគ្រប់ហាន ៖

"ថាសព្វសត្វតែកតគ្រប់គ្នា សុទ្ធសឹងជាមានកម្មប៉ាំប្រាណ ហើយទទួលកម្មនោះឥតលោះខាន គឺត្រូវបានផលជាទុក្ខ · សុខ ។ កម្មជាបាបអកុសលតែងផ្តល់ឲ្យ សព្វសត្វសោយទោសពៀរវេរទុក្ខ ឯកម្មល្អតែងឲ្យសត្វសោយសុខ ទោសគ្រប់មុខខ្វាក់ខ្វាយឆ្ងាយពុំជិត ។

ពិតមែនហើយសត្វលង់ក្នុងភពបី ពុំឃើញជាក់អរិយសច្ចពិត
ត្រូវតណ្ហាអវិជ្ជារួបរឹត ទើបងងឹតបិទខ្ទាក់លក្ខណញាណ ។
កាលអន្ទោលយោលលង់ក្នុងត្រៃវដ្ដ ត្រាច់រង្គាត់ព័ត់វៀងទៀងតែបាន
សោយសុខខ្លះទុក្ខខ្លះឥតលោះខាន តាមមូលដ្ឋាននៃកម្មជាធម្មតា ។
បើកុសលឲ្យផលដល់ហើយក្ដី ពេលនោះត្រូវសត្វផងរងសុខា
អកុសលឲ្យផលដល់កាលណា ពេលនោះជាវិបត្តិសត្វសោយទុក្ខ ។

អធិប្បាយថាសត្វពិតទៀងទាត់ ដែលរង្គាត់វិលវល់គ្មានយល់មុខ
តែងបានផលជាសុខ ឬ ជាទុក្ខ តាមទំនុកនៃកម្មប្រចាំប្រាណ ។
បើបុណ្យដែលខ្លួនស្អាងសាងសន្សំ ឧបត្ថម្ភពុំបាត់សត្វក៏បាន
ដូចលាភ,យស,សរសើរ,សុខសម្រាន្ត ហើយនឹងបានគេជះគបះក្រៃ ។
ទាំងជាទីស្រឡាញ់ពេញចិត្ដា នៃមនុស្សាសត្វសព្វគ្រប់យប់ថ្ងៃ
ទាំងទេព្ដាយក្សយង់គង់ពិស្ម័យ ឲ្យពរជ័យស្រីសុខសព្វវេលា ។
ទៅទីណាទោះក្រក៏ឥតខ្វះ គេសំពះវៃហាហូរគេបូជា
ក្នុងទីនោះឈ្មោះឡើងថ្កើងមហិមា ដូចចន្ទ្របូណ៌មីរស្មីស្វាង ។
ដូនដុនជាបាបកម្មតាមមកទាន់ ក៏ប្រែក័ន្ដត្រឡប់សព្វបែបយ៉ាង
ទាំងគេជះយស, លាភ, ភ័ក្ដសំណាង គ្មានសំអាងរុងរឿងថ្កើងទៅទៀត ។
គ្មានមនុស្សទេព្ដាណាស្រឡាញ់ គេតែងខ្ទាញ់រអើមខ្ពើមបង្បៀត
គ្រប់កន្លែងតែងមានគេបៀនបៀត សូម្បីញាតិគង់ធ្មៀតបៀតបៀនប្រាណ ។

អ្នកនោះប្រែបែរជាអនាថា ទៅទីណាគេស្អប់មិនរាប់អាន
តែងរងទុក្ខមុខជ្រប់គ្រប់ទីឋាន ពុំដែលបានថ្កានថ្កើងឡើងរាសី ។
ដូចអំពិលអំពែករស្មើតិច ក្ដីព្រិចៗ តែក្បងរងក្រី
កាលអាទិត្យប្ដូររះច្បាស់ឡើងវិញ ក៏បាត់បង់រង្សីស្មើថ្ងៃ" ។

ស្ដេចទ្រង់សង្កេតអនិច្ចា អកុសលអាត្មា តាមទាន់នៅកាយ ។
ឱះឱ! អនិច្ចារូបកាយ ទុក្ខឥតស្រាយ កម្មកាយអ្វីអើយ ។
ឲ្យព្រាត់ពីរដ្ឋមកហើយ ទុក្ខឥតល្ហែល្ហើយ ថែមហើយថែមទៀត ។
កម្មអ្វីក៏បេះតែបៀត ត្រួតហើយត្រួតទៀត ឥតមានស្រាកស្បើយ ។
មកុដជាកញ្ចប់បាយហើយ មិនតែម៉្លោះឡើយ ព្រះខាន់តែរូវ ។
ក្លាយជាកណ្ដៀវប្រេតប្រេវ ឥឡូវនេះក្បូរ សេះតែកំពៅ ។
ប្រែខ្លួនបែរជាសត្វគោ អស់ទ្រព្យសេដ្ឋោ ព្រាត់ចេញអស់ហើយ ។
ឱះឱ! អនិច្ចារូបអើយ ឥតមានអ្វីឡើយ កំដររង្វង់សោះ ។
នៅតែព្រះពស្ត្រ១ស្នោះ ស្លៀកដណ្ដប់នោះ កំដរអង្គអញ ។
អនិច្ចាអាត្មាគួរខ្មាញ់ ស្បែកសាច់ឈាមអញ ពុរពងអស់ហើយ ។
ព្រះចៅសិរីសោរ៍ត្រាណត្រើយ ព្រាត់គ្រឿងអស់ហើយ នៅតែក្លូសា ។
ទ្រង់សោកវិយោគខ្លាំងក្លា ព្រះមហាក្សត្រា ស្រឡាញ់សេះក្រែ ។
ទើបនាំឲ្យព្រះហ្ឫទ័យ ពេលកលស្មើរក្បួយ ប្រល័យផ្នា ។
ពុំដឹងទីងធ្វើយ៉ាងណា ទើបតាំងចិត្តា យាត្រាតាំងសៅ ។

លុះដល់ថ្ងៃរាបទាបទៅ  បរមបមពៅ  ទន់អស់កាយា ។
ស្រេកឃ្លានព្រោះគ្មានភោជនា  ក្រៀមក្រំក្រក្រា  ល្ហិតៗល្ហៃៗ ។
ទើបចូលទៅជ្រកដើមជ្រៃ  ដុះនៅជាយព្រៃ  សម្រាកកាយា ។
លុះបានស្រាកស្រាន្តហើយណា  ស្តេចក៏យាត្រា  ចូលកាត់ព្រៃជ្រៅ ។

បទកាកគតិ

ចមកពនរបតី ស្តេចត្រាច់ទៅទី ស្មារតីហ្មងហ្មង់ អត់តាំងព្រះស្ងោយ ទន់ខ្សោយកាយអង្គ អំណោះយូរលង់ ពីរបីថ្ងៃហើយ ។ សេចក្តីស្រេកឃ្លាន រឹងលុករុកពន ឥតឯស្បែស្បើយ ពុំដែលបានសោយ ព្រះស្ងោយតិចឡើយ ល្ហិតៗល្ហើយៗ ទន់ស្បើយកាយា ។ ស្តេចខំដំរង់ ស្មារតីផ្ចិតផ្ចង់ ឲ្យគង់ជន្មា ខំយាងតិចៗ តាមដោយមាគ៌ា យូរតិចទៅណា បានឃើញវត្តលោក ។ ស្តេចគន់គិតថា ៖ "ឱអង្គអាត្មា អត់បាយបរិភោគ បើច្នេះអញទៅរកសូមបាយលោក ក្រែងលោកអគ្យោគ ឲ្យទានភោក្តា" ។ គិតហ្នោះពុំនៅ ស្តេចយាងវៀងទៅ ឃើញនេន ១ ណា នៅជិតវិហារ តែឯងឯកា ស្តេចមានចិន្តា ស្នេហាពេកណាស់ ។ ទើបមានវាចា នឹងសាមណេរថា ៖ "ឱលោកអម្ចាស់ ខ្ញុំមកពីឆ្ងាយ អត់បាយយូរណាស់ ព្រះគុណអម្ចាស់ ប្រោសយកបុណ្យណា ។ ខ្ញុំឃ្លានពេកណាស់ សូមព្រះគុណម្ចាស់ ឲ្យខ្ញុំទៅវ៉ា ហើយសូមអាស្រ័យ ពីរបីទិវា លុះល្ហែវេទនា នឹងលាចេញទៅ" ។ (មានត)

# រឿងសាមកុក

## កណ្ឌទី ២០

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ស៊ុនហុកបានឮដូច្នោះក៏ឆ្លើយតបនឹងខុងយ៉ុងថា ៈ អ៊ួនសៀវនឹងមានប្រាជ្ញាបេះគិត បុន្តឹងមានថ្វីដៃច្បាំងកាំងដល់ខ្លាំងពូកែក៏ទេ ។ គ្រាន់តែមានទាហានច្រើនប៉ុណ្ណោះ ដែលនឹងឲ្យទៅនិយាយសម្រួលជាផ្លូវមេត្រីវិញនោះមិនគួរសោះ ។ ខុងយ៉ុងឆ្លើយថា អ៊ួនសៀវគ្មានសតិបញ្ញា គ្មានថ្វីដៃខ្លាំងពូកែក៏មែនហើយ តែមានស្រុកចំណុះជាច្រើនតំបន់ ទាំងស្បៀងអាហារក៏បរិបូណ៌ព្រម, មួយទៀតបានសឹមផុយ, ទៅហ៊ុវ, គួតោ, ហាងគីទាំង ៤ នាក់នេះ សុទ្ធតែមានសតិបញ្ញាជាទីប្រឹក្សារបស់អ៊ួនសៀវ ឯទាហានឯកដែលមានថ្វីដៃនោះ គឺ តៀនហាង, ឈីស៊ុវ, ផាន់លៀង,

ប៊ុនធីវ, កោឡាំ, គៀវខាប់, អ៊ុខេង មនុស្សទាំងនេះ សុទ្ធតែមានដំរេះប្រាជ្ញានឹងថ្វីដៃខ្លាំងពូកែទៀងត្រង់នឹងអ៊ួនសៀវ ព្រមទាំងកូនទាហានក៏មានយ៉ាងច្រើន ហេតុម្តេចអ្នកទៅប្រមាថមើលងាយអ៊ួនសៀវដូច្នេះ ៗ

ស៊ុនហុកបានស្តាប់ដូច្នោះក៏អស់សំណើចហើយតបថា សេនាឯកអ៊ួនសៀវដែលមានប្រាជ្ញានឹងថ្វីដៃខ្លាំងពូកែនោះ នឹងកប់ទុកជាចំណានមិនបានទេ ដ្បិតគៀនហាងនោះជាមនុស្សអាក្រក់កាចសាហាវ, ទៅហ៊ីវនោះមានបញ្ញាក៏មែន តែជាមនុស្សល្មោភ ធ្វើការអ្វីច្រើនតែខូចការនោះ, ស៊ីមជួយជាមនុស្សអួតបេះ ទោះបីនរណានិយាយត្រូវក៏ប្រកាន់ថាខុស, ហងគីនោះជាមនុស្សជាងសំដី រកហារយកជាការមិនបាន, ទាំង ៤ នាក់ដែលជាទីប្រឹក្សាអ៊ួនសៀវនោះ សុទ្ធតែជាមនុស្សមានទិដ្ឋិមានះដណ្តើមគ្នាយកត្រូវទៅដោយខ្លួន ៗ ឯសេនាឯកដែលមានថ្វីដៃទាំង ៧ នាក់នោះមិនស្គាល់ច្បាស់ទីបង្ទីបាន បើបានធ្វើសឹកធំគ្រានេះឃើញថានឹងបាប់ខ្លួនបានជាប្រាកដ ឯកូនទាហានដែលមានច្រើនប៉ុន្មាន គ្រាន់តែបណ្តាយបាញ់បណ្តាយឈ្នះប៉ុណ្ណោះ ៗ ខុងយ៉ុងបានស្តាប់ដូច្នោះក៏នៅស្ងៀម ៗ

ចូចូបានឃើញខុងយ៉ុងនៅស្ងៀមដូច្នោះ ក៏អស់សំណើចហើយថា "ស៊ុនហុកនេះធ្លាប់ប្រមាណការអ្វីមិនបេះខុសសោះ គួរជឿគំនិតដែលគិតការម្តងនេះត្រូវដូចគំនិតរបស់យើង" ថាហើយក៏បាត់ឡេវគាយនឹងអងគុងឲ្យលើកទាហាន ៥ ម៉ឺន យកទង់ជ័យសម្រាប់ចូចូទៅផង នឹងឲ្យ

លើកទៅវាយយកស្រុកឈីជីវ ។ ជៀយុកឆ្លើយថា ដែលលោកនឹងប្រើ ឡៅតាយនឹងអងតុងលើកកងទ័ពចេញទៅនោះ ខ្ញុំបាទយល់ឃើញថា អ្នកទាំង ២ តស៊ូក្បីដៃឡៅពីមិនបានទេ ។ ចូឆូតបថា "អ្នកនិយាយនេះ ត្រូវហើយ ដែលយើងប្រើឡៅតាយនឹងអងតុងទៅគ្រានេះ បីដូចជា ឲ្យទៅទល់កងទ័ពឡៅពីទុកប៉ុណ្ណោះទេ គឺមិនឲ្យកងទ័ពឡៅពីចូលដល់ គ្នានឹងកងទ័ពអ៊ួនសៀវ" ថាហើយចូឆូក៏បង្គាប់ឡៅតាយនឹងអងតុងថា ដែលអ្នកនឹងលើកកងទ័ពទៅនោះ កុំអាលចូលទៅតច្បាំងកាប់យកស្រុក ឈីជីវឡើយ ឲ្យតាំងទ័ពពទុកជាទីការពារប៉ុណ្ណោះ បើកងទ័ពយើង ច្បាំងនឹងអ៊ួនសៀវខាងនេះ មានជ័យជំនះវេលាណា គង់នឹងលើកទៅ សន្ទប់ខ្ទប់គ្នាវាយយកស្រុកឈីជីវតែម្តង ។ ឡៅតាយនឹងអងតុងក៏គំនាប់ លាចូឆូ ទទួលនាំយកទាហាន ៤ ម៉ឺនលើកចេញទៅតាមបង្គាប់ចូឆូ ។ ក៏ចាត់ចែងទាហានលើកចេញទៅប្រមាណ ២០ ម៉ឺនទៅដល់តំបន់គួតរ ក៏ ឲ្យបញ្ឈប់កងទ័ពតាំងបន្ទាយនៅទីនោះ ចម្ងាយផ្លូវទៅដល់បន្ទាយអ៊ួន-សៀវប្រហែល ៨០០ សិន ( ៣២ គីឡូម៉ែត្រ ) ។

អ៊ួនសៀវដឹងថា កងទ័ពចូឆូលើកមកតាំងនៅដូច្នោះ ក៏ប្រឹក្សា នឹងសេនាទាហានទាំងពួងថា យើងនឹងលើកចេញតច្បាំងនឹងកងទ័ពចូឆូ ឬប្រការម្តេច? ។ ការប្រឹក្សាគ្នានេះមិនបានដាច់ស្រេច ព្រោះហេតុ ទៅហ៊ុវមានសេចក្តីតូចចិត្តថា សុំមជួយបានជាបាឡាត់ទ័ពបង្គាប់បញ្ជាលើ

សេនាទាហានទាំងពួង ឈើស៊ីវកឹតួបចិត្តទឹងអ្នកសៀវថា ខ្លួនទឹងប្រឹក្សាការពារការស៊ើកអ្នកសៀវមិនយល់ឃើញផង, អ្នកសៀវទើបមិនបានចេញច្បាំងទឹងប៊ូឆ្ល, ទ័ពអ្នកសៀវនៅត្រៀមទុកតាំងពីខែភទ្របទលុះដល់ខែកត្តិក ។

ប៊ូឆ្លឃើញថាអ្នកសៀវមិនបានលើកទ័ពចេញច្បាំង ក៏ត្រិះថាអ្នកសៀវនឹងធ្វើកលតែងទ័ពលើកទៅខ្ញុំវាយយកក្រុងហ៊ូគោ ទើបប្រើចុងប៉ាជាសេនាលីប៉ោឲ្យលើកទាហានទៅចាំស្កាត់ផ្លូវ ត្រង់ប្រទល់ដែនស្រុកឈើជីវ កុំឲ្យទាហានអ្នកសៀវនឹងទាហានឡៅពីដើរទៅមករកគ្នាបាន ប្រើអ៊ុកិមទឹងលីតៀន លើកទាហានជាកងមុខទៅចាំស្កាត់ផ្លូវទន្លេហាងហោ ត្រង់ដែនស្រុកហ៊ូគោ កុំឲ្យទាហានអ្នកសៀវនឹងទាហានឡៅពីដើរទៅមករកគ្នាបាន ប្រើហោយិនលើកកងទ័ពធំទៅតាំងនៅតំបន់គួតរ ខ្លួនប៊ូឆ្លក៏លើកត្រឡប់ចូលទៅក្នុងក្រុងហ៊ូគោវិញ ហើយធ្វើសំបុត្របាត់បំរើសេះឲ្យកាន់ទៅដល់ឡៅតាយទឹងអងគុង ឲ្យបង្គំលើកទ័ពចូលវាយទំលាយយកស្រុកឈើជីវឲ្យបាន ។

ឯឡៅពីដែលនៅក្នុងក្រុងឈើជីវលុះដឹងថា កងទ័ពលើកទៅបោះនៅជិតក្រុងបម្ងាយពីព្រំដែនប្រហែល ៨០០ ស៊ិន (៣២ គីឡូម៉ែត្រ) ក៏នៅមិនទាន់ច្បាស់ជាទាហានប៊ូឆ្លនោះ នរណាជាមេទ័ព ។ ឡៅពីក៏មិនបានចេញច្បាំង គ្រាន់តែត្រៀមសេនាទាហានឲ្យឡើងរក្សាសែន

បន្ទាយកាយ យាមល្បាតខាត់ក្រវែលជាយ៉ាងមាំមួន ហើយតាំស្តាប់ដំណឹងអួនសៀវ ដែលលើកមកច្បាំងនឹងប្អូននោះ នឹងឈ្នះឬចាញ់ប្រការម្តេចក៏មិនបានជាក់ច្បាស់សោះ ។

បំរើសេះនាំសំបុត្រប្អូននោះទៅប្រគល់ ឲ្យឡៅតាយនឹងអងតុងក្នុងបន្ទាយ ៗ ឡៅតាយនឹងអងតុងដឹងសេចក្តីហើយ ទើបប្រឹក្សាគ្នាថា នរណានឹងលើកចេញទៅ វាយយកស្រុកឈើជីវជាមុន ៗ ឡៅតាយនិយាយនឹងអងតុងថា មហាឧបកជប្រើយើងជាមេទ័ពមក ត្រូវអ្នកលើកទ័ពទៅវាយយកស្រុកឈើជីវមុនយើងចុះ ៗ អងតុងតបថា មហាឧបកជឲ្យយើងលើកទ័ពមកនោះ នឹងបានបង្គាប់ចំពោះឲ្យអ្នកធ្វើមេទ័ពតែឯងក៏ទេ គឺបង្គាប់ឲ្យខ្ញុំនឹងអ្នកលើកទាហាន ៥ មុឺនមកជាមួយគ្នា បើអ្នកនឹងតាំងខ្លួនជាមេទ័ពតែឯងនោះខ្ញុំមិនព្រមផងទេ ៗ ឡៅតាយតបថា អ្នកនឹងខ្ញុំប្រឹក្សាគ្នាមិនចុះរុះសោះ បើដូច្នេះត្រូវសរសេរអក្សរ ២ តួ មួយថាមុន មួយថាក្រោយ ហើយឲ្យលូកចាប់ដោយផ្សង បើនរណាបានតួអក្សរមុនឲ្យលើកទ័ពទៅច្បាំងមុន បើនរណាបានតួអក្សរក្រោយឲ្យលើកទៅច្បាំងជាក្រោយ ៗ អងតុងយល់ឃើញត្រូវ ក៏សរសេរអក្សរជា ២ តួតាមសំដីហើយផ្សងចាប់ អងតុងចាប់បានអក្សរមុន ឡៅតាយចាប់បានអក្សរក្រោយ ទើបបែងទាហានពាក់កណ្តាលឲ្យអងតុងលើកទៅវាយយកស្រុកឈើជីវ ៗ

(មានត)

# ណាលៈ និង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(ត—ចប់)

---

ព្រាហ្មណ៍ឈ្មោះ សុទេវៈ (Sudeva) ដើររករហូតដល់ក្រុងចេទី (Chédis) ។ ព្រះករុណានឹងឯកអគ្គមហេសីទ្រង់ទទួលដោយរាក់ទាក់ ។ នៅពេលដែលព្រាហ្មណ៍ថ្លែងនូវសេចក្តីអរគុណ ចំពោះព្រះភក្ត្រនៃព្រះចៅក្រុងនោះ ព្រាហ្មណ៍ស្រាប់តែឈប់នៅស្ងៀម... ។

ព្រះករុណា មានបន្ទូលសួរថា: "ចុះមានការអ្វីបានជាឈប់ដូច្នេះ ព្រាហ្មណ៍បណ្ឌិត?" ។

ព្រាហ្មណ៍ទូលតបថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះករុណាព្រះរាជានុញ្ញាត ឲ្យទូលព្រះបង្គំនិយាយនឹងនាងដែលជាសំឡាញ់ នៃព្រះរាជបុត្រីព្រះអង្គបានបន្តិច" ។ ព្រាហ្មណ៍ទូលហើយក៏សំឡឹងទៅព្រះនាងទមយន្តី ។ ព្រះករុណាទ្រង់ឆ្លើយថា: "បើសិនជានាងនោះសុខចិត្ត អ្នកឯងអាចនិយាយនឹងនាងបាន" ។

ព្រះនាងឆ្លើយថា: "ខ្ញុំម្ចាស់សុខចិត្តឲ្យព្រាហ្មណ៍នេះនិយាយនឹងខ្ញុំម្ចាស់បាន" ថាហើយព្រះនាងក៏ធ្វើសញ្ញាឲ្យព្រាហ្មណ៍ដើរមកតាម

ព្រះនាងដែលថយចេញឆ្ងាយពីព្រះករុណា ទើបព្រះវររាជជននី ។ ព្រាហ្មណ៍សុទេវៈ ក៏ផ្ដើមនិយាយថាៈ "ទូលព្រះបង្គំជាខ្ញុំមកពីប្រទេសដែលព្រះនាងជ្រាបស្រាប់ហើយ ពីព្រោះព្រះនាងមានរូបរាងដូចជាម្ចាស់ក្សត្រីដែលទូលព្រះបង្គំដើររកណាស់ គឺជាព្រះរាជបុត្រីនៃព្រះបាទភិមៈ" ។ ព្រះនាងមានបន្ទូលសួរដោយរួសរាន់ថាៈ "យី! ចុះកូនខ្ញុំយ៉ាងណាទៅ?" ។ ព្រាហ្មណ៍ទូលតបដោយញញឹមថាៈ "ព្រះរាជបុត្រទាំងពីរព្រះអង្គសុខសប្បាយគ្រប់ព្រះអង្គទេ អាទិទេពមានព្រះទ័យសន្ដោសជួយថែរក្សាព្រះរាជបុត្រព្រះនាង ដូចជាព្រះបិតាព្រះនាងដែរ" ។ ព្រះនាងទមយន្ដីទ្រង់រំជួលព្រះទ័យខ្លាំងពេក ដោយបានឃើញព្រាហ្មណ៍សុទេវៈ នាំដំណឹងពីព្រះរាជបុត្រមកទូលទ្រង់ឲ្យជ្រាប ព្រះនាងនឹកដល់ព្រះវរបិតានៃព្រះបាទនាលៈ ហើយក៏ទ្រង់ព្រះកន្សែងសោក ។ ព្រះអង្គម្ចាស់ក្សត្រីសុនន្ទា (Sunanda) លុះឃើញព្រះនាងសោកក៏ទ្រង់រត់ទៅទូលព្រះមាតាថាៈ "ព្រះមាតា! សូមទ្រង់ទតនាងដែលជាសំឡាញ់ខ្ញុំម្ចាស់ មិនដឹងជាព្រាហ្មណ៍នោះនាំដំណឹងអ្វីមកប្រាប់នាងទេ ស្រាប់តែនាងយំសស្រាក់" ។ ព្រះរាជជននីមានបន្ទូលថាៈ "ចូរកូនទៅហៅព្រាហ្មណ៍នឹងនាងមកនេះ" ។ ព្រាហ្មណ៍សុទេវ នឹងព្រះនាងទមយន្ដី ចូលទៅជិតព្រះមហាក្សត្រី ។ ទ្រង់សួរថាៈ "អ្នកទាំងពីរនាក់ហាក់ដូចជាស្គាល់គ្នា ហើយខ្ញុំបានយល់ថានាងនេះជាកូនអ្នកត្រកូលខ្ពស់,

តើឥឡូវនេះ នាងអាចប្រាប់យើងថា ឪពុកនាងឈ្មោះអ្វី? ប្តីនាងឈ្មោះអ្វីបានឬទេ? យើងនឹងរាប់អាននាង ហើយនឹងជួយឧបត្ថម្ភនាងផង" ៗ

ព្រះនាងទមយន្តីនៅតែទ្រង់ព្រះកន្សែងអួលអាក់ ៗ ព្រាហ្មណ៍ក៏ឆ្លើយជួសថា: "ព្រះមហាក្សត្រីដ៏ប្រសើរ! ទ្រង់មិនលែងជ្រាបនូវព្រះចៅក្រុងវិទភ៌ៈទេ ដែលមានព្រះនាមថាព្រះបាទភិមៈ ព្រះនាងនេះទ្រង់ព្រះនាមទមយន្តី ជាព្រះរាជបុត្រីនៃព្រះបាទភិមៈនោះ មួយទៀតព្រះមហាក្សត្រីគង់ទ្រង់បានជ្រាបនូវព្រះមហាក្សត្រនៃពួក និសធៈ ដែលទ្រង់ព្រះនាមព្រះបាទនាលៈដែរទេ? ព្រះនាងដែលនៅចំព្រះភក្ត្រនេះជាព្រះអគ្គមហេសីនៃព្រះបាទនាលៈនោះ, នាលៈជាស្តេចអភ័ព្វ ទ្រង់បានបោះបង់ចោលព្រះរាជអាណាចក្ររបស់ព្រះអង្គ ហើយព្រះនាងទមយន្តីទ្រង់ព្រមព្រៀងចេញចាកព្រះរាជធានី ទៅតាមព្រះអង្គនៅពេលដែលទ្រង់ខ្ចាត់ចេញពីប្រទេស ..." ៗ ព្រះវររាជជននីទ្រង់មានបន្ទូលកាត់ព្រាហ្មណ៍ថា: "យី ព្រាហ្មណ៍! នាងនេះជាព្រះរាជបុត្រីព្រះបាទភិមៈឬ? ដូច្នេះតើបានជាយើងកួបចិត្តស្រឡាញ់តាំងពីដំបូង" ហើយទ្រង់បែរព្រះភក្ត្រមករកព្រះនាងថា: "ឯងជាកូនរបស់បងស្រីយើង ម្តាយឯងនឹងយើងជាព្រះរាជបុត្រីព្រះបាទសុទម័ន (Sudamam) ដែលជាស្តេចពួកទសណ៌ៈ (Daçarnas) ៗ

ព្រះនាងឆ្លើយតបព្រះសវនីយ៍ថា: "ខ្ញុំម្ចាស់ក៏ដឹងដែរ ប៉ុន្តែខ្ញុំម្ចាស់លាក់ឈ្មោះព្រោះខ្ញុំម្ចាស់ខ្មាស, ដោយសារតែខ្ញុំម្ចាស់អៀនខ្មាសនេះ

ហើយ បានជាខ្ញុំម្ចាស់ចេះតែលើកការសន្ទនាជាមួយនឹងព្រាហ្មណ៍នៅទីក្រុងនេះ ស្អែកជាខាន់ស្អែក ខ្ញុំម្ចាស់មិនបានពណ៌នាអំពីសេចក្ដីវេទនារបស់ខ្ញុំម្ចាស់ទេ ខ្ញុំម្ចាស់មិនបានប្រាប់ព្រាហ្មណ៍ថាអ្នកណាមួយជាប្ដីខ្ញុំម្ចាស់ទេ ខ្ញុំម្ចាស់ខ្លាចក្រែងមិនជិតលេចឮការសំងាត់របស់ខ្ញុំម្ចាស់" ។ ព្រះមហាក្សត្រីនឹងព្រះរាជបុត្រីសុនន្ទា ទ្រង់មានព្រះទ័យសោមនស្សពន់ពេកក្រៃពេលនោះ ។

*

* *

ភាគទី ៤៩

ព្រះនាងទមយន្តីយាងទៅគង់នៅជួបជុំជាមួយព្រះវររាជបិតា នឹងបុត្រាបុត្រី ។ ព្រះនាងសព្វព្រះហឫទ័យនឹងព្រះរាជបុត្រណាស់ ។ ប៉ុន្តែកាលណា ព្រះនាងគង់នៅស្ងាត់តែមួយព្រះអង្គឯង ទ្រង់ព្រះកន្សែងសោកដោយនឹកដល់ព្រះបាទនល:ជាទីស្រឡាញ់របស់ព្រះនាង ។

ថ្ងៃមួយ ព្រះនាងត្រាស់ហៅព្រាហ្មណ៍សុទេវ: ហើយមានព្រះបន្ទូលថា " សុទេវ: ! ខ្ញុំស្គាល់គតិបណ្ឌិត នឹងសេចក្ដីវៃឆ្លាតរបស់អ្នក ព្រោះអ្នកបានទៅរកខ្ញុំឃើញនៅកណ្ដាលក្រុងចេទី ចូរអ្នកអាណិតខ្ញុំ ដរាបណាព្រះបាទនល:មិនគង់នៅទីនេះជាមួយនឹងខ្ញុំទេ ដរាបនោះខ្ញុំគ្មានសប្បាយបន្តិចឡើយ បើដូច្នេះ ចូរអ្នកធ្វើដំណើរទៅរកព្រះអង្គនៅគ្រប់ដំបន់ " ។

ព្រាហ្មណ៍ទូលតបថា: "ព្រះមហាក្សត្រ! ទូលព្រះបង្គំនឹងធ្វើតាមព្រះរាជសវនីយ៍ ទូលព្រះបង្គំនឹងទៅរកឲ្យគ្រប់ព្រះរាជអាណាចក្រទាំងអស់ ហើយបើព្រះអង្គគង់ជីវិតនៅឡើយ ទូលព្រះបង្គំនឹងនាំស្តេចត្រឡប់មកនគរវិទេភៈវិញ" ។

ព្រាហ្មណ៍ដើរសួរសព្វទីកន្លែង តាំងតែពីស្តេចសោយរាជ្យមានកិត្តិនាមល្បីល្បាញ រហូតដល់ពួកស្មូមយាចក ប៉ុន្តែគ្មានឃើញព្រះបាទនលៈសោះ ។ ក្រោយបង្អស់ព្រាហ្មណ៍សុទេវៈបានចូលដល់ក្រុងអយុធ្យា ចូលទៅគាល់ព្រះបាទរិតុបទ៌ៈ ។ ព្រាហ្មណ៍ពុំបានជ្រាបនូវកលល្បាយរបស់ព្រះបាទនលៈទេ ព្រាហ្មណ៍នោះរៀបនឹងដើរចេញមកហើយ ស្រាប់តែវរស្ន័យ ដែលជានាយគង្វាលសេះស្រែកហៅឲ្យឈប់ ហើយប្រាប់ទៅព្រាហ្មណ៍ថា: "ព្រាហ្មណ៍! ក្នុងចំណោមគង្វាលសេះដែលធ្វើការក្រោមបង្គាប់ខ្ញុំ មានបុរសកំសត់ម្នាក់ចេះតែត្អូញត្អែរថាគ្មានឈប់ឈរ វាប្រាប់គេថាវាឈ្មោះវាហុកៈ តែបើវានឹកដល់ប្រពន្ធរបស់ពួកម៉ាកវាឡើងវាយំ វាថាស្រីនោះសំឡាញ់វាបានរត់ចោលនៅកណ្តាលព្រៃ ថាសំឡាញ់វាបានធ្វើឲ្យរលាយអស់ទ្រព្យសម្បត្តិ ខ្ញុំខ្លាចក្រែងរឿងនេះជារឿងរបស់វា ប៉ុន្តែវាត្រឡប់ថាគេទៅវិញ ព្រោះរឿងដែលវានិយាយនោះ ដូចរឿងព្រះបាទនលៈដោយពិតណាស់" ។ ព្រាហ្មណ៍សុទេវៈក៏ដើរតាមវរស្ន័យទៅក្នុងកន្លែងចិញ្ចឹមសេះ ហើយលប

មើលវហុកៈនៅទីនោះ នៅពេលនោះវហុកៈកំពុងតែយំថ្ងូរដូចកាលសព្វមួយដង: "ដឹងជានាងនៅឯណា! មិនដឹងជាជោគវាសនាអាក្រក់នាំនាងទៅឯណា! ដឹងជានាងស្លាប់ដោយអត់អាហារ ឬដោយគ្មានទឹក! ឬមួយជាស្លាប់ដោយសត្វសាហាវហែកស៊ីជាចំណី! ឱលោកអើយ នាងទៅឯណាទៅ?" ។ ព្រាហ្មណ៍នោះប្រងស្តាប់ហើយក៏និយាយនឹងវរស្ម័យថា: "កាលពីដើម ខ្ញុំធ្លាប់បានស្តាប់សំឡេងព្រះបាទនាលៈ ហើយខ្ញុំនៅចំណាំសំណួរសំឡេងនោះ" ។

វរស្ម័យឆ្លើយឡើងថា: "មែនហើយព្រាហ្មណ៍! នៅពេលដែលខ្ញុំឮសំដីវហុកៈ ខ្ញុំស្មានតែព្រះបាទនាលៈដែរ" ។

– "ព្រះបាទនាលៈ មានរូបឆោមល្អលើសមនុស្សក្នុងលោក តើអ្នកណានឹងអាចផ្លាស់កែវព្រះអង្គកើត បើវហុកៈអាក្រក់ផុតនិស្ស័យយ៉ាងនេះ" ។

វរស្ម័យឆ្លើយថា: "វហុកៈជំនាញខាងបរសេះណាស់ បើដូច្នេះយើងគិតយកវិជ្ជានេះដាក់ឲ្យឃើញសាកសិទ្ធ ព្រោះខាងល្បឿនសេះគ្មានអ្នកណាស្មើនឹងព្រះបាទនាលៈទេ" ។

ព្រាហ្មណ៍ឆ្លើយថា: "បើដូច្នោះចាំពីរបីថ្ងៃទៀត យើងនឹងយកវិជ្ជារបស់វហុកៈមកសាកមើល" ថាហើយក៏ចេញពីក្រុងអយុធ្យាទៅ ប៉ុន្តែពីរបីថ្ងៃក្រោយមកព្រាហ្មណ៍ត្រឡប់មកវិញ ចូលទៅថ្វាយបង្គំព្រះ

បាទវិតុបនិៈទៀត ហើយទូលព្រះអង្គថា: " ក្រាបទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង! ព្រះនាងទមយន្តី ទ្រង់លែងសង្ឃឹមនឹងបានឃើញព្រះបាទនាលៈវិញហើយ ព្រះបាទភិមៈនឹងព្រះនាងបានព្រមព្រៀងគ្នានឹងរើសរកព្រះស្វាមីជាថ្មីមួយទៀត ហើយប្រមូលស្តេចគប់នគរឲ្យយាងចូលមកប្រជុំសន្និបាតគាល់ហរិព៌ហាមង្គល បើដូច្នេះ សូមស្តេចយាងទៅកុំខាន" ។

ព្រះបាទវិតុបនិៈមានព្រះបន្ទូលថា: "យើងនឹងទៅទីប្រជុំមិនខាន, អ្នកណាដែលមិនសប្បាយចិត្ត បើបានរួមរស់នាជាមួយនឹងព្រះនាងទមយន្តី នឹងបានសប្បាយចិត្ត" ។

ព្រាហ្មណ៍សុទេវៈទូលតទៅទៀតថា: "ប៉ុន្តែសូមទ្រង់យាងប្រញាប់ ព្រោះគេត្រូវបើកប្រជុំនៅពេលស្អែកនេះ" ។

— នៅពេលស្អែក! តើក្នុងមួយថ្ងៃឲ្យខ្ញុំទៅដល់ប្រទេសព្រះបាទភិមៈម្តេចបាន បើឆ្ងាយម៉្លេះ? ខ្ញុំគ្មានសេះឲ្យលឿនល្អហើយគ្មានទាំងបរើយ៉ាងចំណាប់អាចនឹងនាំខ្ញុំឲ្យដល់ទៅប្រទេសវិទភិៈ ក្នុងមួយថ្ងៃបានទេ" ។

ព្រាហ្មណ៍ទូលថា "សូមស្តេចមានព្រះឱង្ការហៅបរើទ្រង់ទាំងអស់គ្នាមក មិនលែងមានអ្នកណាម្នាក់អាចនាំទ្រង់ទៅឯក្រុងវិទភិៈបានទេ" ។

ព្រះបាទវិតុបន៍ៈ ត្រាស់បង្គាប់ឲ្យហៅអ្នកគង្វាលសេះមកទាំងអស់ ហើយទ្រង់មានព្រះបន្ទូលថា "ព្រះនាងទមយន្តីត្រូវការរើសប្តីមួយទៀត

មហាសន្និបាតអាពាហ៍ពិពាហមង្គល ត្រូវបើកប្រជុំនៅពេលស្អែកនេះ, តើក្នុងចំណោមអ្នករាល់គ្នា មានអ្នកណាមួយអាចនាំខ្ញុំទៅក្រុងវិទេហៈ ឲ្យទាន់ពេលស្អែកនេះបានឬទេ?"

វេហុកៈញ័រមៃនោសពោតនា ឈានមួយជំហានទៅមុខ ហើយបង្គំទូលថា: "ទូលព្រះបង្គំជាខ្ញុំ" ។ ស្តេចទ្រង់ទតដោយឆ្ងល់ ។ វេហុកៈឆ្លើយបញ្ជាក់ម្តងទៀតថា: "ព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំនឹងជានាជូនទ្រង់ឲ្យបានសំរេចដូចព្រះរាជបំណង សូមទ្រង់កុំព្រួយ ឲ្យតែគេរៀបទឹមព្រះរាជរថឲ្យទូលព្រះបង្គំចុះ ស្អែកនេះយើងនឹងបានដល់ព្រះរាជអាណាចក្រនៃព្រះបាទភិមៈ" ។

ព្រាហ្មណ៍សុទេវៈនិយាយទៅកាន់រស្ម័យថា "ខ្ញុំស្មានថាខ្ញុំមុខជានឹងរកព្រះបាទនលៈឃើញ" ។

* * *

## ភាគទី ៣០

ព្រឹកនោះ ព្រះនាងទមយន្តីតើនឡើងដោយមានព្រះហឫទ័យរីករាយណាស់ ។ ពន្លឺថ្ងៃនៃព្រះអាទិត្យចាំងចូលមកក្នុងបន្ទប់ព្រះនាង ។ នៅក្នុងឧទ្យានគេឮសូរសំឡេងបក្សាយំយ៉ាងពីរោះ ។ ព្រះនាងបានទ្រង់ព្រះសណ្តាប់នូវសំរែកដំរីកោទនឹងសំរែកសេះ បន្ទឺសំណូរឮពីឆ្ងាយសំដែងសេចក្តីរីករាយ ។ ព្រះនាងទមយន្តីទ្រង់យាងឡើងទៅលើយ៉នៃមហាប្រាសាទ ដែលមានវាយោព្រឹកព្រហាមបក់ត្រជាក់ល្អ ហើយនឹងមាន

ផ្ការីកស្គុះស្គាយ ៗ នៅលើកលស្មៅពណ៌បៃតង មានក្ងោកកំលេងកំសាន្ត ៗ ឯក្ងាននៃព្រះបរមរាជវាំងនាំគ្នាហែលត្រសងក្នុងស្រះស្រី ៗ

ពេលព្រឹកប្រកបដោយអាកាសល្អធ្វើឲ្យព្រះនាងក្សាន្តព្រះហឫទ័យ ព្រះនាងទតឃើញរទេះមួយគួចំឡែកបរតាមផ្លូវមួយឆ្ងាយដាច់ស្រយាល ៗ រទេះនោះបរលឿនណាស់ ហើយកាន់តែមកជិតឡើងៗ សារថីពាក់អាវពណ៌ក្រហម ៗ បន្ដិចរទេះចូលដល់ក្នុងក្រុងហើយមកឈប់នៅពីមុខទ្វារព្រះបរមរាជវាំង បុរសពាក់អាវក្រហមចុះពីរទេះ រត់ចូលមកក្នុងមហា-ប្រាសាទ រត់កាត់តាមថែវ ព្រមទាំងស្រែកថា. "ទមយន្តី! ទមយន្តី!" ដល់ហើយក៏ដោះអាវក្រហមគ្រវាត់ចោល ព្រះនាងស្គាល់ច្បាស់ជាព្រះបាទនាលៈ ក៏ស្រែកទទួលទៅវិញថា: "នាលៈ! នាលៈ! ម្ចាស់សំឡាញ់!" ៗ

ស្ដេចទាំងពីរព្រះអង្គទ្រង់ឱបក្រសោបគ្នាទៅវិញទៅមក ជាយូរដោយសេចក្ដីរឭក នឹងត្រេកអរ ៗ

* *

## ភាគទី ៣១

ព្រះបាទរិតុបទិៈ ទ្រង់ឆ្ងល់នឹងឃើញវាហុក លោតចូលតាមទ្វារព្រះបរមរាជវាំងដូចជាមនុស្សឆ្កួត ៗ ពួកឆ្មាំទ្វារនាំស្ដេចយាងទៅជួបនឹងព្រះបាទភិមៈ ទ្រង់គ្មានឃើញគេរៀបទីប្រជុំសន្និបាតសោះ គ្មានឃើញស្ដេចណាឬព្រះអង្គម្ចាស់ណាមួយសោះ គេទទួលទ្រង់តែមួយអង្គឯងដោយ

កិត្តិយស ។ ព្រះបាទកិមៈទ្រង់សាកសួរអំពីសេចក្តីសុខទុក្ខផ្សេងៗ ហើយ មានបន្ទូលថា ទ្រង់សព្វព្រះរាជហឫទ័យនឹងបានឃើញព្រះភក្រ្តព្រះអង្គ ហើយទ្រង់ត្រាស់សួរទៅទៀតថាៈ "តើស្តេចយាងមកមានការអ្វីជាប្រញាប់ឬ បានជាទ្រង់ស្តេចមកដោយមិនបានឲ្យដំណឹងយើងជាមុន? តើមានសត្រូវចង់បៀតបៀនស្តេចឬ? ទ្រង់ត្រូវការនឹងជំនួយយើងទេ? បើទ្រង់ត្រូវការ សូមទ្រង់មានបន្ទូលមកចុះ" ។

ព្រះបាទវិតុបនិៈ មិនដឹងឆ្លើយយ៉ាងណា ក៏គង់នៅស្ងៀមបែបអៀនក្នុងព្រះទ័យ ។ ព្រះបាទកិមៈក៏ត្រាស់សួរដោយសំដីស្រទន់ទៀតថាៈ "ព្រះអង្គមានការអ្វី មានបន្ទូលមកចុះ" ។ ព្រះបាទវិតុបនិៈក៏ទូលតបថាៈ "ព្រះករុណាដ៏ប្រសើរ! ទូលព្រះបង្គំមានបំណងចង់មកថ្លែងសេចក្តីមេត្រីភាព នឹងសេចក្តីគោរពចំពោះព្រះភក្រ្តព្រះអង្គតែប៉ុណ្ណោះទេ" ។ នៅពេលនោះ ព្រះនាងទមយន្តីនឹងព្រះបាទនាលៈ កាន់ព្រះហស្តគ្នា ព្រមទាំងមានព្រះរាជបុត្រា នឹងព្រះរាជបុត្រី យាងតាមក្រោយព្រះអង្គដោយមានព្រះភក្រ្តសប្បាយរីករាយផង ចូលមកក្នុងព្រះរាជបាហុនដ្ឋាន (មន្ទីរទទួលភ្ញៀវនៃស្តេច) ។ ព្រះបាទវិតុបនិៈ ទ្រង់មានប្រាជ្ញាវ័យទ្រង់ដឹងភ្លាមថា អ្នកដែលបាននាំទ្រង់មក គឺព្រះបាទនាលៈទើបទូលស្តេចថាៈ "ទូលព្រះបង្គំចង់នាំវីរបុរសឲ្យមកជួបនឹងព្រះនាងដែលតែងទ្រង់ទុក្ខខ្លាំង" ។

*

* *

## ភាគទី ៣២

ពេលនេះជាពេលបុណ្យយ៉ាងគគ្រឹកគគ្រេងនៅក្នុងក្រុងពួកវិទភិៈ ។ ព្រះបាទនាលៈ ទ្រង់យាងត្រឡប់មកក្រុងពួកទិសធៈដោយពេញកិត្តិយស ។ ទ្រង់យកឡុកឡាក់ ហើយទ្រង់ហៅទ្រង់បុ៉ស្ការៈ មកក្រសាលជាមួយនឹងទ្រង់ទៀត ។ ម្តងនេះអាទិទេពជួយឧបត្ថម្ភទ្រង់ទៅវិញ ទ្រង់ឈ្នះបានព្រះរាជអាណាចក្រវិញ ប៉ុន្តែដោយទ្រង់យល់ថា បុ៉ស្ការៈហាក់ដូចជាវេទនាពេក ទ្រង់ក៏បែកព្រះរាជអាណាចក្រមួយចំហៀងឲ្យសោយរាជ្យ ។ ព្រះបាទនាលៈ នឹងព្រះនាងទមយន្តី ទ្រង់សោយរាជសម្បត្តិប្រកបដោយសេចក្តីសុខ សេចក្តីចំរើនរហូតដល់អវសាន ។

ចប់

### ត្រូវឃើញឆ្ងាយ កុំឃើញជិត

អ្នកធ្វើប្រយោជន៍ដល់ជាតិ គឺអ្នកមើលឃើញឆ្ងាយ, អ្នកនោះឯងទុកជាវីរបុរស។ តែងមិនឃើញជិត យ៉ាងអ្នកដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួនទេ;

ធ្វើម្តេចហ្ន៎! ឲ្យខ្មែរគ្រប់ថានៈមើលឃើញឆ្ងាយគ្រប់គ្នាឡើង!

យ. អ.

# ដំណើរតាមខ្យល់ក្នុងគគណ្ឌារ:

## លោក ផេង-ជឿវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

នាងឡីឡាឱបបងៈដោយមេត្តា ហើយពោលថា: "ឱ មាសសម្លាញ់ប្អូនអើយ!" ។

អាឥស្សរាតាភ័យខ្លាចស្លាប់ ។ ដើមឡើយ គឺនាងទេតើដែលបង្គាប់ឲ្យរត់ចេញពីកងទាហានតួរគី ឥឡូវត្រឡប់ឲ្យទៅសូមទីពឹងកងទាហាននេះវិញ ។ សូររំពងមាត់ផ្ទៃព្រៃទាំងឡាយឮមកដល់នាងតាមខ្យល់ពេលល្ងាច ។ អាឥស្សរាតាខ្លាចព្រឺញ័ររអស់ទាំងខ្លួន ។ នាងប្រះហើយអង្វរប្អូនថា:

- ទៅ! ឡីឡា! ទៅ! កុំទុកឲ្យបងស្លាប់! ។

ខណៈនោះ នាងឡីឡាសំឡឹងមើលបងកំសត់ ហើយមានចិត្តអាណិតរកទីបំផុតគ្មាន ។ នាងនិយាយប្រាប់បងស្រីថា:

- សូមបងចាំប្អូនត្រង់ហ្នឹងចុះ ប្អូនសន្យានឹងមកជួយសង្គ្រោះអ្នកបងជាមិនខាន ។

រួចនាងដើរកាត់វាលខ្សាច់ទៅ ប្រកបដោយសេចក្ដីក្លាហានហួសប្រមាណខ្លួនជាស្រីក្រមុំ ។ នាងចំប្រាំឡើងផ្នូរខ្សាច់ លុះបានដល់

ខាងលើកាលណា នាងលាន់មាត់តែខ្លួនឯង ។ នៅឯណោះឆ្ងាយបន្តិច ប្រហែលមួយគីឡូម៉ែត្រ នាងឃើញគណៈលោកតាម៉ាព្រេក មានទាហានតួរគីដើរពីខាងក្រោយ ត្រាប់ទៅសន្សឹម ៗ សំដៅទីក្រុង ។

នាងកុមារិកាទាំងពីរនាក់ នឹកស្មានថាខ្លួនអាចត្រាប់កាត់វាលខ្សាច់បាន ទេ! ក្មេងកំសត់ នាំគ្នាដើរវិលវង់ពីផ្លូវមួយទៅផ្លូវមួយ គ្មានបានឆ្ងាយប៉ុន្មានពីកន្លែងដែលចេញសោះ ។

នាងឡីឡានឹកថាប្រាកដជាព្រះអាឡស់ជួយនាង ។

បំណែកពួកឈ្លើយដើរទៅមុខតិចៗ បើរត់ នាងអាចទៅទាន់ភ្លាម ។ នាងឡីឡាមិនបាច់គិតច្រើន ព្រោះប្រកបដោយមេត្តាប្រាថ្នាចង់ជួយសង្គ្រោះជីវិតរបស់បងស្រី ។ នាងឡីឡាភ្លេចនឹកដល់ការអស់កំឡាំង គ្រោះថ្នាក់ ជើងសង្ក្រៀរ នាងស្ទុះរត់លើដីខ្សាច់ពណ៌ក្រហមព្រឿង ៗ ដោយរស្មីព្រះអាទិត្យជិតយប់ សំដៅពួកឈ្លើយដើម្បីដោះទុក្ខបងស្រី ។

*
* *

នាងឡីឡាមកក្រាបចុះក្បែរជើងសេះរបស់នាយទាហានម្នាក់ ។ គឺជាទាហានម្នាក់ដែលរដ្ឋាភិបាលតួរគីបញ្ជូនមកក្នុងស្រុកចំណុះ ដោយបញ្ឈប់លែងឲ្យធ្វើការនៅឯស្រុកកំណើត ។ គាត់នេះ ស្រុកដើមកំណើតនៅកស្ទិទ៍ គេតែងហៅគាត់ថា ព្រិទ្ធបាលទោម៉ារីយោ ។ គាត់បានឡើងដល់ឋានន្តរស័ក្តិតូចមួយនេះ មិនមែនបានដោយវិជ្ជាទេ

គឺបានដោយសារធ្វើការយូរ ៗ គាត់ទុកជាតិអាព៉ាប់ជាមនុស្សក្រោយគេ ហើយមានសិទ្ធិចង់សម្លាប់ ឬទុកជីវិតអ្នកណាក៏បានតាមចិត្ត ៗ

កាលពីក្មេង គាត់តែងគោចរតែក្នុងតៀមទឹកស្រវឹងនាក្រុងកុងស្តង់ទីណុប រហូតដល់ជាប់ស្លុក ហើយបើនឹងរៀបចំកិច្ចការអ្វីគាត់ច្រើនប្រើតែអាវុធជាប្រមាណ នាំធ្វើឲ្យគេពល់គ្នារំខានដោយសារ ៗ ថ្វីបើគាត់ជាអ្នកកាន់សាសនាម៉ាហូមេត ប៉ុន្តែគាត់នេះគ្មានគោរពបទបញ្ញត្តិណាមួយរបស់ព្រះអង្គសោះ គាត់ប្រព្រឹត្តផឹកតែទឹកស្រវឹង ទាល់តែក្អកឡើងក្រហមដូចក្អែកអាអូត មុខក្រហមដូចមុខមាន់គក ហើយច្រើនខឹងរគូងរគាំង ៗ នាយទាហានទាំងឡាយស្អប់គាត់ណាស់ ប៉ុន្តែអធ្យាស្រ័យអត់អោនឲ្យដោយសារដឹងថាគាត់ប៉ិនទ្រាំក្នុងមុខក្រសួង ៗ ម្យ៉ាងទៀតពួកវរសេនីយ៍ទាំងនោះក៏ជាមនុស្សមិនល្អប៉ុន្មាន ៗ ក្នុងជាន់មុន វដ្ឋកិបាល ក្នុងស្តង់ទីណុបទុកក្រុងទ្រីប៉ូលីនេះជាកន្លែងសម្រាប់និរទេសដែលគេតែងបញ្ជូនអ្នកធ្វើរាជការ ឬក្រុមទាហានមក ៗ ហេតុដូច្នេះហើយបានជាកងវរសេនីយ៍ធំនេះ មានច្រើនសុទ្ធតែក្រុមទាហាននិងនាយទាហានមានជាតិនិងកិរិយាមារយាទមិនបរិសុទ្ធល្អទេ ៗ

ចំណែកក្រុមទាហានមិនសូវចូលចិត្តនឹងលោកព្រិន្ទបាលទោ ម៉ារ៉េយោនេះសោះ ព្រោះលោកនេះមានចំណេះពីសំណាក់នាយទាហានអាឡឺម៉ង់ ហើយតែងតែយករបៀបសណ្តាប់ធ្នាប់អាឡឺម៉ង់មកប្រព្រឹត្ត ៗ តាមវិន័យខាងលើនេះ គេឃើញលោកម៉ារ៉េយោប្រព្រឹត្តអំពើយង់ឃ្នងជាច្រើន ៗ

មានមួយថ្ងៃ   គាត់កាត់ស្លឹកត្រចៀករបស់ទាហានម្នាក់ដែលនៅក្រោមបង្គាប់គាត់ ៗ ម្ដងទៀត គាត់វាយសេះដែលគាត់ជិះទាល់តែស្លាប់ ។ កាលដែលសេះនោះកំពុងដកបង្កាមាន់   គេឃើញចំបើងដែលដាក់ឲ្យសេះនោះដេកប្រឡាក់សុទ្ធតែឈាម   ព្រោះលោកម៉ារិយ៉ោតែងជិះសេះណាដែលលោកដឹងថាជាសេះកៀច   ដោយពាក់ស្បែកជើងបាតបន្លាមុតដូចកាំបិតកោរ ។

លោកព្រឹទ្ធបាលម៉ារិយ៉ោងក់ប៉ាក់ប៉ើកនៅលើខ្នងសេះ ព្រោះស្រវឹងស្រាកាប្យនក្នុងកំប៉ុងដែលព្យួរទឹងខ្សែក្រវាត់ នៅជាប់ចន្ទោះដាវទឹងកាំភ្លើងរ៉ឺវ៉ល្វែរ ។ លុះសេះទប់ង៉ក់ ទើបលោកម៉ារិយ៉ោបើកភ្នែក ហើយឃើញនាងឡូឡាលុតជង្គង់នៅពីមុខសេះដោយអាការអន់វន់ ៗ គាត់ញញឹមហើយសួរថា:

- មកពីណា នាងក្រមុំ? ។

ពួកទាហានខ្វះទឹងអ្នកជិះអូដ្ឋ ដែលដើរពីក្រោយកំឈប់តាម, ក្នុងបណ្ដាអាក៉ប់ទាំងឡាយ នាងឡូឡាស្គាល់លោកតាម៉ាព្រុក ៗ កាលចេញពីជ្រលងភ្នំមកគាត់ដើរមុនគេ ប៉ុន្តែគាត់ចាស់ដើរមិនលឿន ក៏ត្រឡប់ជានៅក្រោយវិញ ៗ លុះបានឃើញមុខលោកតាជានាយគណៈចរាចរ៍ នាងក្រមុំត្រឡប់មានកំឡាំង ហើយមានសេចក្ដីសង្ឃឹមបន្ដិចចក្នុងចិត្ត ៗ នាងងើបឡើង ហើយមានវាចាថា:

— ខ្ញុំសូមអង្វរលោក សូមលោកមេត្តាជួយស្រង់អាយុចង្រៃខ្ញុំផង គាត់នៅតែម្នាក់ឯងក្នុងពេលខ្យាចឯណោះ ។

លោកម៉ារ៉ៃយ៉ាក្រឡេកឃើញនារីនេះ តម្រេកក៏កើតមានឡើង ហើយបញ្ចេញអាការឱ្យឃើញតាមភ្នែក ។ សំឡឹងពីខាងក្រៅសំពត់ ដែលត្រូវញើសជាមជិតជាប់នឹងរាងកាយនៃនាង គាត់នឹកស្មានដល់ទៅ យុវសណ្ឋានអាក្រាត ដល់ស្តន់យ៉ាងក្បុំដូចផ្លែទន្សាយ មានចុងពណ៌សូកូឡាផ្កាប់នឹងទ្រូង ដល់ទៅសាច់ពោះសរលីងដូចបណ្តូលចេក ហើយ គាត់គិតថា បងស្រីក៏មិនបាញ់ប្អូនប៉ុន្មាន ។ រូបទាហានស្រវឹងនេះញ៉ាំង រាគគ្គិឱ្យឆេះឡើង មានបំណងនឹងប្រព្រឹត្តអព្រហ្មចរិយធម៌ ចំពោះលើ រូបនាងកុមារិកាទាំងពីរ គាត់នេះចង់បានស្រីកំណាន់យូរណាស់ហើយ ចង់ធ្វើឱ្យដូចជានាយទាហានទាំងពួង គឺមានស្រីកំណាន់ចំពោះខ្លួននៅ បំរើជានិច្ចដូចជាទាសី ។

លោកព្រិន្ទបាលផញ្ជឹងមួយស្របក់ តែភ្នែកសំឡឹងព្រះអាទិត្យ ដែលលិចចុះឯជើងមេឃ ហើយពោលមួយទៅលើក្បាលក្បួនដំណើរដែល មានលោកវ៉ៃសេនីយ៍ទោ សេលីម ជាអ្នកបញ្ជាការ ។ នាយទាហាន នេះត្រូវជាក្មួយរបស់ព្រះចៅមុយនីរ ប៉ុន្តែ ជាមនុស្សមិនរឡេះរឡោះក្នុង មុខក្រសួង ហើយមិនសូវអត់ទោសចំពោះលោកព្រិន្ទបាលនេះផង ។

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងគតិលោក

## លោកសមិន ម្ចត្យេនជិមៈ តែង

## លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ក្នុងពេលនោះ, នៅក្នុងព្រះនគរអវន្តី មានព្រាហ្មណ៍ម្នាក់តែងគោរពបូជានាងទេវីជាទេវតារក្សាប្រទេស ។ នាងទេវីមានព្រះទ័យត្រេកអរនូវការវន្ទានៃព្រាហ្មណ៍នោះ បានមកបង្ហាញរូបឲ្យព្រាហ្មណ៍នោះឃើញ ហើយពោលសរសើរព្រាហ្មណ៍ជាអនេកបរិយាយ ហើយសួរថា: "ឱព្រាហ្មណ៍អើយ, អ្នកឯងប្រាថ្នាចង់បានអ្វីក្នុងលោកនេះ" ។ ព្រាហ្មណ៍នោះកាលបានពណ៌នាអំពីគុណសម្បត្តិនៃនាងទេវី ក៏តបទៅវិញថា: "ឱទេវី, បើនាងមានចិត្តអាណិតខ្ញុំដោយស្មោះត្រង់ ខ្ញុំសូមឲ្យនាងធ្វើឲ្យខ្ញុំផុតពីសេចក្ដីចាស់ជរានិងមរណៈ" ។ នាងទេវីបានស្ដាប់នូវពាក្យព្រាហ្មណ៍នោះហើយ ក៏មានអំណរជាយ៉ាងក្រៃលែង ហើយប្រគល់ផ្លែឈើមួយទៅព្រាហ្មណ៍នោះរួចប្រាប់ថា: "បើកាលណាអ្នកឯងបរិភោគផ្លែឈើនេះ អ្នកឯងនឹងផុតពីសេចក្ដីចាស់ជរានិងមរណៈ" ។ រួចនាងទេវីក៏បាត់ខ្លួនក្នុងពេលនោះ; ព្រាហ្មណ៍ក៏ត្រឡប់ទៅគេហដ្ឋានខ្លួនវិញ ។ ដល់ថ្ងៃស្អែក, ព្រាហ្មណ៍នោះបានបំពេញករណីយកិច្ចចំពោះនាងទេវី ដោយ

លុបព្រះភក្ត្រ, បូជានូវផ្កាឈើផ្សេងៗ ហើយប្រុងប្រៀបទីនឹងយកផ្លែឈើនោះមកបរិភោគ ទទួលមានចិត្តមួយគិតថា: "ខ្ញុំអញជាអ្នកសូមយាចកជាទុគ៌តបុគ្គល, គេមានប្រយោជន៍អ្វី ទីងឲ្យជីវិតអញមានថេរវេលាតទៅទៀត? ព្រះបាទពារាណសី ជាព្រះមហាក្សត្រិយ៍ទ្រង់ទសពិធរាជធម៌, ការដែលធ្វើឲ្យព្រះអង្គមានទីឃាយុ នាំឲ្យបានប្រយោជន៍ដ៏ឧត្តមចំពោះបុគ្គលទាំងពួងជាច្រើន" ។ កាលព្រាហ្មណ៍នោះពិចារណា យ៉ាងនេះហើយ, ក៏ធ្វើដំណើរទៅកាន់ព្រះរាជនិវេសនដ្ឋានក្រាបបង្គំថ្វាយនូវផ្លែឈើនោះទៅព្រះមហាក្សត្រិយ៍ ហើយក៏ទូលទ្រង់ឲ្យជ្រាបនូវរឿងសព្វគ្រប់ ។ ព្រះមហាក្សត្រិយ៍ទ្រង់ទទួលផ្លែឈើនោះហើយ ក៏បានប្រគល់នូវគ្រឿងឥស្សរិយយសជាច្រើនឲ្យដល់ព្រាហ្មណ៍; ឯព្រាហ្មណ៍នោះក៏វិលទៅគេហដ្ឋានខ្លួនវិញ ។ មហារាជបានចូលទៅកាន់ក្រឡាព្រះបន្ទំនៃពួកស្រីស្នំ ក៏បានព្រះរាជទាននូវផ្លែឈើនោះទៅព្រះនាងហេទី ហើយទ្រង់បានថ្លែងរឿងរ៉ាវឲ្យព្រះនាងស្ដាប់សព្វគ្រប់ប្រការ ។ ព្រះនាងហេទីមានចិត្តប្រតិព័ទ្ធស្នេហាចំពោះព្រះរាជទីប្រឹក្សាទីមួយ ក៏យកផ្លែឈើនោះទៅប្រគល់ឲ្យព្រះរាជទីប្រឹក្សានេះ ។ ព្រះរាជទីប្រឹក្សានោះ មានសេចក្ដីស្នេហាចំពោះស្រីស្នំម្នាក់ទៀត ក៏បានយករឿងរ៉ាវទៅពណ៌នាប្រាប់នាងហើយក៏ឲ្យនូវផ្លែឈើនោះ ។ ឯស្ត្រីស្នំនេះបានទទួលផ្លែឈើនោះហើយក៏សម្រេចក្នុងចិត្តថា: "បើអញយកផ្លែឈើនេះទៅថ្វាយព្រះបាទ

ពាក្រែហាំ មុខជាអញបានសម្បត្តិទ្រព្យច្រើន" ។ កាលគិតយ៉ាងនេះហើយ នាងក៏នាំយកផ្លែឈើនោះទៅថ្វាយព្រះមហាក្សត្រិយ៍ ។ ទ្រង់ទទួលនូវផ្លែឈើនោះ ដោយមានព្រះរាជវិចិកិច្ឆាថា: "ផ្លែឈើនេះអញបានឲ្យទៅព្រះនាងហានី, តើសេចក្តីស្រឡាញ់ព្រះនាងហានី ចំពោះនាងទាសីការនេះយ៉ាងណាទៅ?" ព្រះមហាក្សត្រិយ៍ទ្រង់ក៏បានត្រាស់បង្គាប់ឲ្យស៊ើបសួររឿងនេះ ហើយក៏ទ្រង់ជ្រាបនូវរឿងរ៉ាវទាំងអស់ ។ ព្រះអង្គក៏មានព្រះទ័យនឿយណាយនឹងលោកាមិស ហើយទ្រង់ជ្រាបច្បាស់នូវសភាពលាមក ដែលកើតពីទ្រព្យសម្បត្តិក្រៅពីនេះ គឺស្ត្រី, ទារក . . . . ល . . . . ។ ព្រះអង្គទ្រង់ព្រះតម្រិះដូចនេះថា "ស្ត្រីនេះអញស្រឡាញ់លើសជីវិតអញទៅទៀត, ឥឡូវនេះអញឃើញដោយជាក់លាក់ថាវាឥតមានស្នេហាមកលើខ្លួនអញសោះឡើយ, បែរទៅជាមានចិត្តប្រតិព័ទ្ធនឹងទីប្រឹក្សាអញវិញ; ទីប្រឹក្សានេះគ្មានចិត្តស្នេហានឹងនាងហានីទេ បែរទៅស្រឡាញ់ស្រីស្នំទៅវិញ; ចំណែកឯស្រីស្នំគ្មានប្រតិព័ទ្ធនឹងទីប្រឹក្សានេះ បែរទៅជាស្រឡាញ់ទ្រព្យសម្បត្តិទៅវិញ ។ ព្រោះហេតុនេះ ការស្នេហាចំពោះស្ត្រី, ទារក បុត្រឯទៀតក្នុងលោកនេះ គឺជាការបំភាន់គំនិតអញសោះ" ។ ព្រះមហាក្សត្រិយ៍ដល់ទ្រង់វិតក្កៈយ៉ាងនេះហើយ ក៏ទ្រង់លះបង់រាជសម្បត្តិ យាងទៅគង់នៅក្នុងព្រៃជារុក្ខមូលនៅទីនោះ ទ្រង់សោយនូវផ្លែឈើដែលព្រះបរេក្ខិតមក, ហើយក៏គ្គង

ចិត្តទៅក្នុងសមាធិយ៉ាងពេញលេញ ។ មហារាជភត្រីហរិមិនមានព្រះរាជឱរស, ព្រះរាជអាណាចក្រក៏គ្មានស្ដេចសោយរាជ្យ ហើយប្រជារាស្ត្រមានសេចក្ដីភ័យខ្លាំង ដោយមានចោរពាលសាមាន្យប្រព្រឹត្តលួចប្លន់កាន់តែមានចំនួនទៅជាច្រើនរាល់ថ្ងៃ ។

មានវេតាលៈ(១) នាមថាអគ្គិ បានតាំងគេហដ្ឋានទៅក្នុងប្រទេសនោះ ។ ចំណែកខាងពួកទីប្រឹក្សា ដោយសេចក្ដីភ័យខ្លាំង បានចាត់ផ្ទេររាជសម្បត្តិមកឲ្យយុវជនម្នាក់ ឈ្មោះសត្រិយៈ ដែលមានលក្ខណៈជាស្ដេច ។ តែថ្ងៃដែលគេយកយុវជននោះមកអភិសេក វេតាលៈអគ្គិមកពិឃាតយុវជននោះ រួចត្រឡប់វិលទៅគេហដ្ឋានវិញ ។ តាំងពីនោះមក, បើពួកទីប្រឹក្សាបានលើកឥស្សរជនណាមួយឲ្យសោយរាជសម្បត្តិ វេតាលៈអគ្គិនោះមកពិឃាតភ្លាម ។ ព្រោះហេតុនេះ គេលែងហ៊ានលើកឥស្សរជនណាមួយឲ្យសោយរាជសម្បត្តិក្នុងប្រទេសនោះ ។ ការប្រព្រឹត្តអំពើពាលទុច្ចរិតនៃពួកចោរឬអសប្បុរស កាន់តែមានអានុភាពខ្លាំងរាល់ទិវារាត្រី ទាល់តែប្រទេសចុះក្នុងស្ថានការណ៍ដ៏លំបាក ។ ព្រះរាជទីប្រឹក្សាបានខំពិចារណារកមធ្យោបាយ ដើម្បីនឹងការពារស្ដេចកុំឲ្យវេតាលៈនោះមកពិឃាតបាន តែព្រះរាជទីប្រឹក្សានេះ មិនអាចរកឧបាយកលណាឃើញឡើយ ។

---

១ វេតាលៈ បិសាចមួយរូប ដែលនៅទីប៉ាឆា មានរិទ្ធានុភាព អាចឲ្យទុក្ខទោសសព្វយ៉ាងដល់អ្នកដែលខ្លួនស្អប់ ឬបំណងនឹងព្យាបាទ ។

មានមួយថ្ងៃ ពួករដ្ឋមន្ត្រីបានធ្វើសន្និបាត, ក្នុងពេលប្រជុំ កំពុងតែវិនិច្ឆ័យរឿងនេះ ស្រាប់តែព្រះបាទវិក្រមាទិត្យ ទ្រង់ក្លែងព្រះអង្គចូលមកក្នុងព្រះរាជមន្ទីរ ហើយមានព្រះឱង្ការសួរទៅកាន់រដ្ឋមន្ត្រីទាំងឡាយថា: "ហេតុដូចម្តេច បានជាព្រះរាជអាណាចក្រនេះ គ្មានព្រះមហា-ក្សត្រិយ៍?" ។ ពួករដ្ឋមន្ត្រីទូលថា: "ព្រះមហាក្សត្រទ្រង់យាងទៅគង់ក្នុងព្រៃ; កាលណាបើយើងខ្ញុំរើសក្សត្រិយ៍អង្គណាមួយ ឲ្យសោយរាជ្យ វេតាលៈអគ្គី ក៏មកបំផ្លាញជីវិតនូវព្រះមហាក្សត្រិយ៍អង្គនោះភ្លាម" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ, ទ្រង់មានព្រះរាជឱង្ការថា: "ឲ្យពួកអ្នកអភិសេកខ្ញុំជាស្តេចក្នុងពេលឥឡូវនេះចុះ" ។ ពួករដ្ឋមន្ត្រីបានឃើញព្រះបាទវិក្រមាទិត្យមានព្រះរាជចរិយាដ៏ថ្លៃថ្នូរ គួរឲ្យសោយរាជ្យជាស្តេចបាន ក៏បានអភិសេកព្រះអង្គជាស្តេច ហើយប្រកាសថា: "តាំងពីថ្ងៃនេះ ព្រះអង្គជាព្រះមហាក្សត្រិយ៍នៅប្រទេសអវន្តី យើងទាំងអស់គ្នា សូមប្រព្រឹត្តតាមព្រះរាជឱង្ការព្រះអង្គគ្រប់ប្រការក្នុងកិច្ចការទាំងពួង" ។ កាលព្រះបាទវិក្រមាទិត្យ ទ្រង់បានសោយរាជ្យជាស្តេចនៅប្រទេសអវន្តី ទ្រង់បានរៀបចំចាត់ការក្នុងព្រះរាជអាណាចក្រពល់ទិវារាត្រី. ប្រទេសក៏បានទទួលនូវសេចក្តីសុខ ។

(មានត)

## សេចក្តីរៀបរៀង

## របស់ព្រះទេពសត្ថា បទុមង្គលោ កឹម-ត្បូ

វត្តឧណ្ណាលោម

អំពី

## ដំណើរទៅកាន់ប្រទេសភូមា

(ត-ចប់)

---

## ពិធីប្រគេនសមណស័ក្តិជាអគ្គមហាបណ្ឌិត បំពោះសម្តេចព្រះមហាសុមេធាធិបតី ជ. ណាត

ក្នុងថ្ងៃទី ២២ ឧសភា ១៩៥៤ នោះ នៅវេលាម៉ោង ១៤, រដ្ឋាភិបាលប្រទេសភូមា បានចាត់ការរៀបពិធីមួយដ៏ឧឡារិក ដើម្បីប្រគេនសមណស័ក្តិដល់សម្តេចនិងព្រះថេរៈឯទៀត ៧ អង្គ នៅគេហដ្ឋានរបស់លោកប្រធានាធិបតី, ជាពិធីយ៉ាងប្លែកអស្ចារ្យដែលប្រទេសយើងមិនធ្លាប់បានធ្វើផងមិនធ្លាប់បានឃើញផង គឺគេរៀបអាសនៈមួយដ៏ខ្ពស់រចនាដោយក្បាច់ក្បូរទឹងផ្កា មានក្លស់បើកបាំងពីខាងលើ មានពួកស្ត្រីក្មេងចាស់ប្រហែល ២០០ នាក់ សុទ្ធតែស្លៀកពាក់ជាឯកសណ្ឋាន អង្គុយតម្រៀបគ្នាពីខាងមុខឈៀងម្ខាងនៃអាសនៈព្រះមហាថេរ ដែលត្រូវទទួលសមណស័ក្តិ, ពួករដ្ឋមន្ត្រីនិងមន្ត្រីជាលំដាប់ព្រមទាំងឥស្សរជន

គំណាងប្រទេសទាំងអស់ ដែលបានអញ្ជើញមកក្នុងពិធីនោះប្រហែល ៣០០ នាក់ ក៏អង្គុយពីខាងមុខឈៀងម្ខាងនៃអាសនៈទាំងនោះដែរ, ពួកព្រះសង្ឃកូមាននិងព្រះសង្ឃតំណាងប្រទេសជាច្រើន ដែលនិមន្តមកក្នុងពិធីនោះ គង់លើអាសនៈពីខាងក្រោយ ៗ ម៉ោង ១៥, វេលាដល់ហើយ មានបុរសម្នាក់ឈរស្រែកឲ្យសញ្ញាភ្លាម, ភ្លេងត្រែតន្ត្រីក៏លាន់ឮរំពងឡើង ៗ ខណៈនោះឯង គេហែសម្ដេចនិងព្រះមហាថេរឯទៀតចេញមកពីក្នុងកន្លែងមួយ, ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងធម្មការកាន់ក្លួងផ្កាដោយដៃទាំងពីរដើរនាំមុខសម្ដេច, បន្ទាប់ពីសម្ដេចមក ព្រះមហាថេរឯទៀត ៗ សម្ដេចនិងព្រះមហាថេរ ៧ អង្គ និមន្តឡើងគង់លើអាសនៈខ្ពស់ដែលគេតាក់តែងបំរុងទុក, ភ្លេងត្រែតន្ត្រីក៏ស្ងប់ស្ងាត់សូរភ្លាម, មាននារី ៨ នាក់សូត្របទសរភ័ញ្ញជាភាសាកូមាព្រមៗ គ្នា អស់វេលា ៥ នាទី, បន្ទាប់មកលោករដ្ឋមន្ត្រីម្នាក់ឡើងសូត្រប្រវត្តិរបស់សម្ដេចជាភាសាកូមា: លោករដ្ឋមន្ត្រីម្នាក់ទៀតឡើងសូត្រជាភាសាអង់គ្លេស, ហើយទើបថ្លែងប្រវត្តិនៃព្រះថេរៈដទៃៗទៀតតាមលំដាប់លំដោយ, បន្ទាប់មក លោកប្រធានាធិបតីឡើងថ្លែងគុណសម្បត្តិរបស់សម្ដេច រួចហើយក៏លើកសញ្ញាប័ត្រនិងត្រាដែលមានក្អាក់និងហឹបតូចដ៏វិចិត្រ ប្រគេនសម្ដេចជាមុនបង្អស់ រួចប្រគេនមហាថេរឯទៀតតៗ ទៅ ៗ ពិធីដែលពណ៌នាមកនេះឯង គឺរដ្ឋាភិបាលមានលោកប្រធានាធិបតីកូមាជាប្រមុខបានប្រគេនសមណស័ក្តិ ចំពោះសម្ដេចព្រះមហាសុមេធាធិបតីសង្ឃ-

នាយកប្រទេសកម្ពុជា ឲ្យឡើងជា អគ្គមហាបណ្ឌិត ប្រទេសភូមា ។ សេចក្តីពិត តាមដែលលោកសង្ឃទៅប្រទេសភូមានិយាយប្រាប់ខ្ញុំថា សមណស័ក្តិអគ្គមហាបណ្ឌិតនេះ សូម្បីព្រះថេរៈទាំងឡាយដែលនៅប្រទេសភូមា ក៏មិនដែលបានដោយងាយ ៗ ទេ លុះតែបរិបូណ៌ដោយគុណសម្បត្តិ - ចរិយាសម្បត្តិនិងចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានវស្សាច្រើនផង ទើបគួរទទួលឋានៈនេះបាន ។ នៅប្រទេសភូមា ព្រះមហាថេរ ដែលបានឡើងសមណស័ក្តិជាអគ្គមហាបណ្ឌិតនេះ មានមិនច្រើនអង្គទេ, មានច្រើនតែសមណស័ក្តិធម្មាចារ្យ ដែលបានដោយការប្រឡង, ប្រហែលដូចជាសញ្ញាប័ត្រសាលាបាលីនៅប្រទេសខ្មែរយើងដែរ ។

## ដំណើរទស្សនាការបូជនីយស្ថាននៅប្រទេសភូមា

ថ្ងៃទី ២៣ ធ្នូ ១៩៥៤, រដ្ឋាភិបាលប្រទេសភូមា បានចាត់ការជូនគណៈប្រតិភូតំណាងប្រទេសផ្សេង ៗ ទាំងព្រះសង្ឃទាំងគ្រហស្ថចំនួន ១៩៦ រូប ដោយអាកាសយាន ៧ គ្រឿងសុទ្ធតែករ៉ារ៉ុ, ទៅកាន់ក្រុងមន្តលេ ដើម្បីពិនិត្យមើលព្រមទាំងនមស្ការបូជនីយដ្ឋានដ៏សំខាន់ ៗ ។ រយៈផ្លូវអាកាសយានពីក្រុងរ៉ង់គូនទៅមន្តលេ ប្រហែល ៤៣៤ ម៉ៃល៍ (ជាង ៦០០ គីឡូម៉ែត្រ) ។ ម៉ោង ៨, យន្តហោះចេញពីស្ថានីយអាកាសយានមង្គលៈដូន, ម៉ោង ១០,៣០ ដល់ស្ថានីយអាកាសយានក្រុង

មន្ទលេ ។ ពួកបរិស័ទជាតិភូមាជាច្រើនទាំងអ្នកជការទាំងប្រជាកស្រ្ត មកដើម្បីទទួលគណៈប្រតិភូទាំងអស់, និមន្តអញ្ជើញដោយរថយន្តឲ្យទៅស្នាក់ក្នុងមហាវិទ្យាល័យមួយដែលទើបនឹងសង់ហើយថ្មី ។ ក្នុងក្រុងមន្ទលេ ហើយទទួលភត្តថ្ងៃត្រង់នៅទីនោះ ។ ម៉ោង ១៣ គណៈប្រតិភូទាំងអស់ ដែលមានលោកចៅហ្វាយក្រុងនិងភាគីនាគរបាលជិះរថយន្តនឹងទោចក្រយានយន្តនាំមុខ, បានទៅនមស្ការចេតិយមួយហៅ មហាម៉ាក់• មុនី (ឬមហាមុនី) នៅចំកណ្តាលក្រុងមន្ទលេ ៈចេតិយនេះធំខ្ពស់មានផ្លូវសណ្ឋានជាជណ្តើរ មានដំបូលស្រួច ។ ជាប់គ្នាពីថ្នល់ចូលទៅប្រហែល- ៣០ម. ទើបដល់តួចេតិយធំដែលមានព្រះពុទ្ធរូបមួយព្រះអង្គធំទ្រង់គង់តែនព្រះភ្នែន ។ នៅអមសងខាងផ្លូវចូលទៅកាន់ចេតិយធំ មានប្រជាជនភូមាទាំងស្រីប្រុសលក់របស់ប្រើប្រាស់គ្រប់មុខ និងផ្កាផ្សេងៗសម្រាប់ឲ្យអ្នកចូលទៅទិញយកទៅបូជា ។ លំដាប់ពីនេះ គណៈប្រតិភូទាំងអស់បានទៅនមស្ការចេតិយធំមួយទៀត ហៅថា ចេតិយមឹងឡុង តាំងនៅខាងទិសអគ្នេយ៍នៃក្រុងមន្ទលេ ដែលព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម ព្រះបាទមឹងឡុង បានសាងឡើង ។ នៅជុំវិញចេតិយនេះមានចេតិយតូចៗ ឋិតនៅជាជួរៗ ។ ក្នុងចេតិយតូចៗនីមួយៗ មានផ្ទាំងថ្មកែវមួយផ្ទាំងៗ ទទឹង១ម. កំពស់ ១ម.៥០ កម្រាស់ជាង១០សង់ទីម៉ែត្រ ចំនួន

៧២៤ ឆ្នាំ ធ្លាក់បាលីព្រះត្រៃបិដកមួយចប់ជាអក្សរភូមា , មានកំពែងធ្វើដោយឥដ្ឋព័ទ្ធជុំវិញពីខាងក្រៅនៃចេតិយទាំងអស់នោះ ។ តមកទៀតបានទៅសម្រាកនៅសាលាធំមួយ មានថ្នាក់ពីរជាន់ជារបស់តាបសឈ្មោះ អ៊ូ-ខន្តី កសាង ។ ពួកបរិស័ទភូមាបានរៀងគេសជ្ជៈដល់គណៈប្រតិភូទាំងអស់ក្នុងសាលានោះ រួចហើយក៏នាំគ្នាឡើងទៅមើលទៅនមស្ការចេតិយធំលើកំពូលភ្នំមន្ទលេ ។ ភ្នំនេះមើលពីខាងក្រោមទៅឃើញខ្ពស់សន្ធឹម, គេធ្វើចេតិយធំដំកល់ព្រះពុទ្ធរូបមួយព្រះអង្គធំទ្រង់ឈរក្នុងចេតិយចំកណ្ដាល, មានជណ្ដើររៀបជាថ្នាក់ៗសម្រាប់ឡើង មានគ្រប់ទិសទាំង ៤, ជណ្ដើរនីមួយៗ តាំងពីជាន់ក្រោមទៅដល់ជាន់លើប្រហែល ២៥០ម ដំបូលប្រកស័ង្កសីដូចគ្នាទាំងអស់ ។ ម៉ោង ១៧,៣០ ទើបត្រឡប់មកឯកន្លែងស្នាក់នៅមហាវិទ្យាល័យក្រុងមន្ដលេវិញ ។

ថ្ងៃទី ២៤ ឧសភា ១៩៥៤ ម៉ោង ៧ ព្រឹកគណៈប្រតិភូទាំងអស់ចេញពីក្រុងមន្ទលេ ដែលមានលោកចៅហ្វាយក្រុងមន្ដលេនឹងក្រុមភ្នាក់ងាររាជការព្រមទាំងពួកឧបាសកជាច្រើនជូនដំណើរផង, បានទៅមើលព្រមទាំងនមស្ការបូជនីយដ្ឋានក្នុងតំបន់ម៉េងគុន ដោយចក្កនាវាធំមួយឈ្មោះប៉ាដោក ( Padauk) ទទឹង ៨ម បណ្ដោយ ៣០ម. តាមទន្លេឥរាវតី ។ ម៉ោង ៨,៣០ ដល់ម៉េងគុន មានពួកភ្នាក់ងាររាជការនឹងអ្នកស្រុកមកនៅរង់ចាំទទួលនៅទីនោះ គណៈប្រតិភូទាំងអស់ក៏ចុះអំពីចក្កនាវាដើរទៅមើល

ព្រមទាំងនមស្ការចេតិយនៅក្នុងតំបន់ម៉ឹងគុនះនោះជាច្រើនកន្លែង, ចេតិយខ្លះកំពស់ ៥០ម. ក៏មាន, ៦០ម. ក៏មាន, ចេតិយតូចៗ ក៏មាន។ ឃើញដេរដាសកប់ពាន់ចេតិយ ៗ ដល់ម៉ោង ១០ ទទួលភត្តថ្ងៃត្រង់នៅវត្តមួយក្នុងតំបន់ម៉ឹងគុន ដែលអ្នកស្រុកចាត់ចែងប្រគេន ៗ លុះទទួលភត្តរួចហើយ គណៈភិក្ខុទាំងអស់ ក៏ចុះជិះចក្រនាវាដដែលតាមទន្លេឥរាវតីទៅតំបន់មួយទៀតហៅសាកែង ឬសាហ្គែង (Sagaing) ។ ម៉ោង ១៣, ចក្រនាវាដល់ចំណតសាកែង, ឃើញមានរថយន្តធំតូចតម្រៀបជាជួរតាមថ្នល់ ទាំងពួកភ្នាក់ងាររដ្ឋការក៏រង់ចាំទទួលនៅទីនោះដែរ, គណៈភិក្ខុទាំងអស់ក៏ចុះពីនាវាហើយឡើងជិះរថយន្តឆ្ពោះទៅកាន់ រាជមណិចូឡាចេតិយ ជាចេតិយមួយយ៉ាងធំ មានកំពែងព័ទ្ធជុំវិញពីខាងក្រៅ, ខាងក្នុងចេតិយនោះ មានព្រះពុទ្ធរូបមួយព្រះអង្គធំគង់តែនព្រះភ្នែន, នាំគ្នានមស្ការចេតិយនោះ ហើយក៏សម្រាកក្នុងយ៉ាចេតិយទទួលកេសជ្ជៈអស់វេលា ៣០ នាទី, រួចហើយក៏ឡើងរថយន្តទៅនមស្ការចេតិយមួយទៀតឈ្មោះ ង៉ាហ៊ាក់ជិ ៗ ចេតិយនេះក៏ធំណាស់ដែរ មានព្រះពុទ្ធរូបមួយព្រះអង្គធំទ្រង់គង់តែនព្រះភ្នែនខាងក្នុង ៗ តពីនេះ គណៈភិក្ខុទាំងអស់ឡើងរថយន្តឆ្លងទន្លេឥរាវតីដោយសាឡាង ត្រឡប់ចូលមកកាន់ក្រុងមន្ត-លេវិញ ៗ ប៉ុន្តែលុះមកដល់តំបន់មួយឈ្មោះ អមរបុរៈ ជាទីក្រុង

ចាស់នៅជិតក្រុងមន្តលេ. ពួកភ្នាក់ងាររាជការនិងប្រជាជនច្រើនរៀបតុ-តៅអី ព្រមទាំងគ្រឿងសក្ការៈផ្សេងៗរង់ចាំទទួលក្នុងទីនេះ ។ គណៈប្រតិភូទាំងអស់បានទទួលគ្រឿងសក្ការៈរួចហើយ គេក៏នាំចូលទៅមើលរោងចក្រត្បាញសំពត់ដោយគ្រឿងមាស៊ីន ឃើញមានរោងតម្បាញគីឈើជាច្រើនកន្លែង និងរោងបោះពុម្ពសាច់សំពត់ជាផ្កាក្បូរផ្សេងៗ, រួចហើយក៏ឡើងរថយន្តមកកន្លែងសំណាក់នៅមហាវិទ្យាល័យដដែលវិញ ។

ថ្ងៃទី ២៥ ឧសភា ១៩៥៦, ម៉ោង៧ គណៈប្រតិភូទាំងឡាយចេញដំណើរពីក្រុងមន្តលេទៅខេត្តប៉ាកាន (ឬប៉ុហ្កាន (Pagan) ហៅតាមឈ្មោះក្រុងចាស់ពីដើម ដែលខ្មែរយើងធ្លាប់ស្គាល់មកថាភូកាម ឬអរិទ្ធមៈពីក្នុងកាលៈព្រេងនាយ ) ដោយចក្រនាវាឈ្មោះប៉ាដោកដដែលតាមទន្លេឥរាវតី មានទាំងលោកចៅហ្វាយក្រុងមន្តលេនិងក្រុមភ្នាក់ងាររាជការជូនដំណើរទៅផង, ម៉ោង ១៨ ដល់តំបន់សាលាស្រុកមួយឈ្មោះញ៉ោងអ៊ូ ក្នុងខេត្តប៉ាកាន, ចក្រនាវាក៏ត្រូវចតឈប់នៅទីនេះ ឃើញក្រុមភ្នាក់ងាររាជការ និងប្រជាជនជាច្រើនមកៈតម្រៀបរង់ចាំទទួលនៅទីនេះដែរ ។ ក្នុងរាត្រីនោះគេរៀបកន្លែងឲ្យគេនសម្តេចសង្ឃក្នុងនាវានោះ ឯព្រះសង្ឃខ្លះទៀត គេនិមន្តឲ្យទៅសម្រាន្តនៅវត្តមួយឈ្មោះវិសុទ្ធារាម ចម្ងាយពីចំណតនាវាឈប់ ប្រហែល ៣ គីឡូម៉ែត្រ ។

ថ្ងៃទី ២៦ ឧសភា, ម៉ោង៧,៣០ គេយករថយន្តតូចពិសេសមួយមកប្រើតែនសម្ដេចគង់ និងរថយន្តធំៗ ជាច្រើនសម្រាប់គណៈប្រតិភូឯទៀត ឲ្យនិមន្ត-អញ្ជើញទៅមើលព្រមទាំងនមស្ការចេតិយ ស្វេស័គុង, ចេតិយសព្វញ្ញូ, ចេតិយអនន្ត (ដែលបំប្រែមកពីពាក្យថាអនន្តប្បញ្ញា) និងចេតិយកុន្ទោបល្លង, ចេតិយទាំងអស់នេះសុទ្ធតែជាចេតិយធំៗ, ក្នុងចេតិយនីមួយៗ មានយ៉ដំបូលលយចេញ មានប្រវែងប្រហែល ១០០ម. ជាផ្លូវសម្រាប់ឲ្យមនុស្សដើរចូលទៅបាន ៗ ខាងក្នុងចេតិយនីមួយៗមានព្រះពុទ្ធរូបធំ ៗ ទង់ឈរក៏មាន, គង់តែនព្រះភ្នែនក៏មាន ៗ លុះដើរមើល-នមស្ការចេតិយធំៗ ក្នុងតំបន់នេះរួចហើយក៏ត្រឡប់ទៅទទួលភត្តថ្ងៃត្រង់នៅវត្តវិសុទ្ធាកម, ចំណែកខាងសម្ដេចគេនិមន្តទៅទទួលភត្តក្នុងនាវាដដែលវិញ ៗ ក្នុងថ្ងៃដដែល ម៉ោង ១៤ គណៈប្រតិភូទាំងអស់ ដែលមានក្រុមភ្នាក់ងាររាជការជូនដំណើរផង, បានទៅនមស្ការចេតិយធំ ៗ ក្នុងព្រះរាជវាំងចាស់ ដែលឋិតនៅក្នុងតំបន់ប៉ាកានដែរ ៗ ក្នុងទីនោះឃើញចេតិយធំតូចច្រើនដេរដាស រាប់រយរាប់ពាន់, ចេញពីទីនោះបានចូលទៅមើលរោងហត្ថកម្មរបស់ជាងរក្មច់ ៗ ក្នុងរោងនោះឃើញពួកកម្មករអង្គុយធ្វើការជាជួរ, មុនដំបូង ខ្លះយកបន្ទោះឫស្សីដែលឋិតសម្រាំងហើយត្បាញតម្រឹងរាងជាប្រអប់មូល ឬបួនជ្រុងធំតូចមានគ្រប មានថតសម្រាប់ដាក់ស្លាថ្នាំក៏មាន, ជាចានធំតូចក៏មាន, ជាចានស្រាក់មានដៃសម្រាប់យួរក៏មាន ៗ ល ៗ ខ្លះទទួលយកទៅ

ទុកដោយម្រ័ក្សណ៍, ខ្លះទទួលយកទៅក្រឡឹងខាត់, ខ្លះទទួលយកទៅធ្លាក់ជារូបក្បាច់ផ្កាភ្ញីផ្សេងៗ, ខ្លះទទួលយកទៅផាត់ថ្នាំពណ៌ផ្សេងៗ, ខ្លះទទួលយកទៅខាត់សម្រេច ៗ របស់ដែលធ្វើរួចហើយ គេយកទៅដាក់តាំងតម្រៀបគ្នាសម្រាប់លក់ ៗ លុះដល់វេលាល្ងាច គណៈប្រតិភូទាំងអស់ក៏ត្រឡប់មកស្នាក់នៅកន្លែងដើមវិញ ៗ ក្នុងគ្រានោះប្រហែលម៉ោង ១៩ ក្រុមភ្នាក់ងាររាជការនិងប្រជាជនព្រមទាំងព្រះសង្ឃភូមាជាច្រើន បាននិមន្តសម្តេចនិងប្រតិភូប្រទេសឯទៀតសុំឲ្យថ្លែងការណ៍ខ្លីៗ នៅក្នុងសុតោងប្យរិចតិយ ៗ

## ដំណើរទស្សនាការទេសភាពនៃប្រទេសភូមា

ថ្ងៃទី ១៧ មករា ១៩៥៤, ម៉ោង ៩ គណៈប្រតិភូទាំងអស់ ក៏បានចេញដំណើរពីស្រុកញ៉ោងអ៊ូ ដោយមគ្គនាវដែលតាមទន្លេឥរាវតី ឆ្ពោះទៅកាន់ស្ថានីយអាកាសយាន ត្រង់កន្លែងដែលគេជីកអណ្តូងយកប្រេងសាំងប្រេងកាតដែលឋិតនៅក្នុងតំបន់ឈ្មោះឡានីវ៉ ៗ ខណៈនោះគណៈប្រតិភូខ្លះ បានឡើងយន្តហោះមួយឆ្ពោះចេញមកក្រុងរង្គូនមុនគេ ៗ ម៉ោង១៤, ៣០ ដល់ស្ថានីយអាកាសយានមង្គលៈដូន សម្តេចនិមន្តចុះពីអាកាសយាន ហើយគង់រថយន្តឆ្ពោះមកកាន់មហាកុដិជិតមហាបាសាណគុហា (មន្ទីរសង្គាយនា) វិញ ដែលគេរៀបបម្រុងទុកប្រគេនពីថ្ងៃមុន ៗ ក្នុងថ្ងៃដដែលម៉ោង ១៦, ៣០ យើងក្រៅពីសម្តេច បានចូលទៅក្រុង

រ៉ង្គូនដោយរថយន្តរបស់ពុទ្ធសាសនសភា ,  គេនាំយើងទៅមើលរោងឧស្សាហកម្មជាច្រើនកន្លែងទៀតគឺ  រោងចក្រធ្វើប្រដាប់ប្រើប្រាស់ដូចចានស្រាក់,  ឆ្នាំងយួរ ។ល។ ធ្វើដោយដែកអាលុយមូ៉ម,  រោងជាងឆ្លាក់ព្រះពុទ្ធរូបថ្មកែវនឹងថ្មើមថ្ម,  រោងជាងសិតឬស្ពាន់ធ្វើព្រះពុទ្ធរូប, ធ្វើឆត្រត្រួតរបនាជាក្បាច់ក្បូរផ្សេងៗ យ៉ាងល្អសម្រាប់ដាក់កំពូលចេតិយ, ធ្វើគងរគាំងចួងជំគួប  នឹងរបស់ប្រើប្រាស់ផ្សេងឯទៀតជាច្រើនបែប,  រោងជាងដេរកាត់ស្បែកជើង ។ល។ ក្នុងទីផ្សាររ៉ង្គូនទាំងមូល  ឃើញច្រើនតែប្រជាជនជាតិភូមាតាំងរបស់លក់ដេរដាសនៅតាមល្វែងផ្ទះផ្សារ,  ក្រៅពីជាតិភូមា  មានជាតិឥណ្ឌានឹងជាតិអង់គ្លេសលាយមួយៗ  ឯជាតិចិនឃើញមានបន្តិចបន្តួចស្ទើរតែរាប់ថាមានពុំបាន,  ចេញផុតពីទីផ្សារបន្តិចមក  ឃើញរូបអនុស្សាវរីយ៍មួយខ្ពស់ត្រដែតធ្វើដោយស៊ីម៉ងត៍  សសរមូលកំពស់ ៦ ម.  មានរូបភាពលោកសង្ឃមួយអង្គុយបីពរឈរពីខាងលើ,  បានសាកសួរលោកដែលនៅប្រទេសភូមា  លោកប្រាប់ថា  រូបនុ៎ះគឺរូបព្រះថេរៈឈ្មោះ អ៊ូ វិបារៈ  ។  លោកនេះ  ជាអ្នកប្រាជ្ញថ្នាក់ដុកទ័រខាងអក្សរសាស្ត្រនឹងភាសាអង់គ្លេស  ព្រមទាំងចេះព្រះត្រៃបិដកផងលោកជាទីស្រឡាញ់រាប់អាននៃប្រជាជនភូមាស្ទើរតែទាំងអស់ ។ កាលពី គ.ស. ១៩៤២  កងទ័ពជប៉ុនចូលមកក្នុងប្រទេសភូមា,  លោកអ៊ូ វិបារៈ  បាននាំប្រជាជនធ្វើបដិវត្តន៍ទាមទារយកឯករាជ្យពីអង់គ្លេស

ប៉ុន្តែលោកនេះត្រូវអង់គ្លេសចាប់ដាក់គុកតាំងនៅឫស្សីហើយលោកម៉ុងព្រម ទទួលទានអ៊ីសោះដកបដល់ក្ស័យជីវិត ។ មួយទៀតលោកដដែលបាន ប្រាប់ថា មានទុបាសកអ្នកពងការម្នាក់ ឈ្មោះ អោងសាំង ជាអ្នក ស្នេហាជាតិប្រមគំនិតគូដៃធ្វើបដិវត្តន៍ជាមួយនឹងលោកអ៊ីវិចារៈ ។ លោក អោងសាំងនេះ ក៏ត្រូវអង់គ្លេសគេចាប់ដែរ ប៉ុន្តែបានគេចវៀសខ្លួន ទៅនៅឯប្រទេសជប៉ុនដល់មក គ.ស. ១៩៤៥ កងទ័ពជប៉ុនមានជ័យ ជំនះលើកងទ័ពអង់គ្លេសក្នុងប្រទេសភូមា ហើយក៏ទៅនាំយកលោក អោងសាំង ពីប្រទេសជប៉ុនមកតាំងឲ្យធ្វើជានាយករដ្ឋមន្ត្រីទទួលឯករាជ្យ ប្រទេសភូមា, លោកអោងសាំងកាន់ការនាយករដ្ឋមន្ត្រីមិនបានយូរប៉ុន្មាន ក៏ត្រូវមនុស្សក្បត់ជាតិលបប្រហារលោកក្ស័យជីវិតបង់ទៅ ។ ក្នុងសម័យ ដែលប្រទេសភូមាបានឯករាជ្យបរិបូណ៌ហើយគេថតពន្លឺករូប លោក អោងសាំង ដាក់គ្រប់ក្រសួងរាជការនឹងស្ថានីយយន្តហោះ ដើម្បីទុកជា អនុស្សាវរីយ ។

ថ្ងៃ ២៨ ឧសភា ១៩៥៤, ម៉ោង ១០ សម្តេចបាននិមន្តទៅទទួល ភត្តនៅគេហដ្ឋាននៃលោកអ៊ូ-តាន់សេង លេខាធិការក្រសួងធម្មការ មួយអន្លើដោយព្រះសង្ឃប្រតិភូខ្លះទៀត ។ មានក្រុមភ្នាក់ងារនគរបាល ជិះទោចក្រយានយន្តអមនាំមុខរថយន្តសម្តេច ជូនដំណើរតាំងទៅតាំងមក, ក្នុងថ្ងៃដដែល ម៉ោង ១៨, សម្តេចនិមន្តដោយរថយន្តរបស់ពុទ្ធសាសន-

សកា ទៅនមស្ការចេតិយធំៗ ក្នុងក្រុងរ៉ង្គូន គឺចេតិយស្វេតាគុង, សូឡេ, បោតាថោង ។ មុនដំបូង សម្តេចនិមន្តទៅទតនមស្ការចេតិយស្វេតាគុង ឬហៅសិង្គុត្តរចេតិយ ប៉ុន្តែពាក្យថា សិង្គុត្តរចេតិយនេះ ប្រជាជនភូមាទាំងអស់មិនសូវដែលហៅទេ ខ្លះក៏មិនស្គាល់ផង ពួកហៅថាស្វេតាគុងៗច្រើនជាង ។ ចេតិយស្វេតាគុងនេះ ធំសម្បើមអស្ចារ្យណាស់ ទំហំខាងក្រោម ៥០០ម. គេរៀបក្បឿមថ្មធ្វើជាជណ្តើរសម្រាប់ឡើង, ខាងលើជណ្តើរគេធ្វើជាដំបូលជាប់បន្តគ្នា មានកំពូលស្រួចៗ ដង្ហែគារចនាដោយក្បាច់ក្បូរផ្សេងៗ តាំងពីខាងក្រោមឡើងទៅទល់នឹងលានចេតិយខាងលើ ។ ជណ្តើរបែបនេះ មានគ្រប់ទិសទាំង ៤; ក្នុងជណ្តើរនីមួយៗប្រវែង ១៥០ ម. នៅអមសងខាងជណ្តើរឡើងទៅនីមួយៗ មានប្រជាជនភូមាទាំងស្រីប្រុសតាំងរបស់ប្រើប្រាស់គ្រប់មុខសម្រាប់លក់ និងផ្កាផ្សេងៗសម្រាប់លក់ឲ្យអ្នកចូលទៅទិញយកទៅបូជាព្រះពុទ្ធរូប, នៅវាលលានចេតិយខាងលើទំហំ ២០០ ម. តួចេតិយធំនៅចំកណ្តាល មានចេតិយតូចៗជាច្រើនតំកល់ព្រះពុទ្ធរូបថ្មកែវនៅព័ទ្ធជុំវិញចេតិយធំ, នៅជុំវិញចេតិយតូចៗនេះ គេក្រាលសុទ្ធតែថ្មើមថ្មទំហំ ២០ម. ជាទីឱកាសវាលសម្រាប់ដើរបាន, នៅជុំវិញទីវាលនេះ មានសាលាតូចធំជាច្រើនតំកល់ព្រះពុទ្ធរូបថ្មកែវទ្រង់ឈរក៏មាន, ទ្រង់ពែនព្រះភ្នែនក៏មាន, ទ្រង់ផ្ទុំក៏មាន ។ នៅចេតិយស្វេតាគុងនេះមិនកំណត់ថាពេលណាជាពេល

ណាទេ ទាំងថ្ងៃទាំងយប់ ឃើញប្រជាជនភូមាស្រីប្រុសក្មេងចាស់ និងលោកសង្ឃខ្លះចុះខ្លះឡើងបន្តគ្នា កាន់ផ្កាយកទៅបូជាព្រះបដិមាគ្រប់កន្លែង, ត្រង់កន្លែងបូជានីមួយៗ ឃើញសុទ្ធតែផ្កាឈើនិងត្រួយព្រីងស្រស់ៗដោតសំពោងនៅនឹងផើងជាជួរៗ, នៅតាមកន្លែងនីមួយៗ ឮសូរតែសូត្រធម៌ទ្រហឹងអឹងអាប់ ៗ លំដាប់ពីនេះ សម្តេចនិមន្តទៅនមស្ការចេតិយសូឡេ និងចេតិយពោធាថោង ទៀត, ចេតិយទាំងពីរនេះក៏ធំណាស់ដែរបន្ទាប់បន្សំនឹងចេតិយ ស្វេតាគុង ឃើញតែប្រជាជនចុះឡើងយកផ្កាទៅបូជាថ្វាយបង្គំសូត្រធម៌ជាធម្មតាដូចគ្នា ៗ រួចកិច្ចនមស្ការទតចេតិយទាំងអស់នេះហើយសម្តេចក៏និមន្តត្រឡប់មកគង់នៅកន្លែងដើមវិញ ៗ ក្នុងពេលឱកាសពីការចូលប្រជុំធ្វើសង្គាយនាម្តងៗ យើងបានជិះរថយន្តពុទ្ធិក-សមាគមជាមួយនឹងលោកភូមាចូលទៅក្នុងទីក្រុងរ៉ង្គូន ស្ទើរតែសព្វកន្លែង, បានសង្កេតមើលប្រជាជនភូមាលក់របស់ផ្សេងៗ នៅតាមផ្លូវ ខាងក្រៅក្រុងក្តី ខាងក្នុងក្រុងក្តី ដូចជានៅទីភោជនីយដ្ឋានជាដើម មិនឃើញមានលក់សុរានិងអ្នកផឹកសុរាទេ, ទើបសួរលោកភូមា លោកប្រាប់ថានៅប្រទេសភូមាទាំងមូលគ្មានផ្ទះធ្វើសុរាទេ កាលពីដើមមានដែរ ប៉ុន្តែរដ្ឋាភិបាលសព្វថ្ងៃបានតាំងច្បាប់បញ្ញត្តហាមដោយដាច់ខាត មិនឲ្យប្រជាជនណាមួយធ្វើសុរាផឹកឬលក់ក្នុងប្រទេសភូមាឡើយ សូម្បីទៅទទួលវិញនាំយកពីប្រទេសក្រៅមកលក់ក្នុងប្រទេសភូមាក៏ពុំបានដែរ ៗ មួយ

ទៀតលោកនិយាយថា គោនិងក្របីសត្វទាំងពីរពួកនេះក៏រដ្ឋាភិបាលបាន តាំងច្បាប់បញ្ញត្តដល់ប្រជាជន មិនឲ្យសម្លាប់យកសាច់ធ្វើជាអាហារឡើយ សូម្បីគោក្របីនោះចាស់ជរាប្រើការមិនកើតក៏ដោយ ព្រោះគេយល់ឃើញថា សត្វទាំងនេះជាពាហនៈដ៏សំខាន់សម្រាប់ប្រើប្រាស់កសិកម្មរបស់មនុស្សបានជាក្នុងប្រទេសភូមា គេបង្កើតសមាគមជាច្រើនកន្លែងសម្រាប់ទទួលចិញ្ចឹមគោក្របីចាស់ៗ ដែលផុតការប្រើហើយ ឬអ្នកណាមួយមានគោក្របីចាស់ជរាប្រើការមិនកើតហើយពិបាកចិញ្ចឹម អាចនាំយកគោក្របីចាស់នោះទៅប្រគល់ឲ្យឬលក់ឲ្យក្រុមសមាគមនោះក៏បាន, ឯក្រុមសមាគមចិញ្ចឹមគោក្របីចាស់ៗ នោះ គេទទួលចិញ្ចឹមដរាបដល់គោក្របីនោះអស់ជីវិតស្លាប់ឯងៗ ។ ប្រយោជន៍ដែលបានសមាគមនោះតែស្បែកប៉ុណ្ណោះ ឯសាច់ត្រូវតែកប់ចោលជាដរាប ។ ត្រង់នេះគួរឲ្យសរសើររដ្ឋាភិបាលប្រទេសភូមា ដែលចេះចាត់ការបំបាត់មុខសុរានិងការបញ្ញត្តិមិនឲ្យសម្លាប់គោក្របីយកសាច់ធ្វើជាអាហារ, ការនេះសមជាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាមែនៗ ប្រទេសកម្ពុជាគួរតែយកតម្រាប់ប្រទេសភូមា ព្រោះជាប្រទេសកាន់ពុទ្ធសាសនាដូចគ្នា ! ។

## បព្វជិតនៅប្រទេសភូមា

នៅប្រទេសភូមា ប៉ែកខាងពុទ្ធសាសនាមានវត្តប្រហែល ២ ម៉ឺនវត្ត មានលោកសង្ឃ ទាំងភិក្ខុ ទាំងសាមណេរ ប្រហែល ៥ ម៉ឺនរូប(១) ។

១ វត្តនីមួយៗ មានព្រះសង្ឃនៅមិនសូវច្រើនដូចជាប្រទេសខ្មែរទេ ។

ភិក្ខុសាមណេរនៅប្រទេសភូមា ប្រើតែចីវរត្រូវគ្នាទាំងអស់ គឺចីពរ ប្រើតែចីពរបញ្ចខ័ណ្ឌ (ចីពរមានខ័ណ្ឌប្រាំផ្ទាំងក្នុងខ័ណ្ឌនីមួយៗ មានកន្ទ្រើងពីរៗ) ឯស្បង់ឬសង្ឃាដី មានខ័ណ្ឌ ៥ មានកន្ទ្រើង ១០ ដូចគ្នានឹងចីពរដែរ, ចំណែកខាងសង្ឃាដីប្រើពីរជាន់ដូចគ្នា, ពណ៌ចីវរទាំងអស់នោះជ្រលក់ទឹកអម្ចត់ឡើងពណ៌ក្រហមជាំ ស្រស់ល្អ មិនមែនដូចពណ៌ជ្រលក់លំក្តូទេ សូម្បីសំពត់ងូតសម្រាប់ស្រង់ទឹកក៏សុទ្ធតែជ្រលក់ទឹកអម្ចត់ដែរ ។

នៅតាមវត្តនីមួយៗ ក្នុងប្រទេសភូមា មានសាលាបង្រៀនបាលីស្ទើរតែគ្រប់វត្ត ទោះបីវត្តណាមិនទាន់មានសាលាបង្រៀន ក៏គង់ភិក្ខុសា-មណេរដែលបួសហើយចេញទៅរករៀនក្នុងវត្តណាមួយដែលមាននៅជិតខាងពុំខាន ពុំសូវនៅទំនេរ, ដោយហេតុនេះ បានជាប្រទេសភូមាសម្បូរបព្វជិតជាពហុស្សូតអ្នកចេះបាលីណាស់ ។ ក្នុងសាលារៀននីមួយៗ ដែលមាននៅតាមវត្តទាំងប៉ុន្មាន ក៏មានការប្រឡងតាមលំដាប់ថ្នាក់លំដាប់ឆ្នាំ. បានសញ្ញាបត្រដូចជាភិក្ខុសាមណេររៀនបាលីនៅប្រទេសកម្ពុជាយើងដែរ ។ មានសាលាជាន់ខ្ពស់មួយទៀតហៅថា សាលាធម្មទូត ឬមហាវិទ្យាល័យ ដែលរាជការទើបនឹងបង្កើតឡើង, សាលានេះក្នុងមួយឆ្នាំៗ រាជការត្រូវជ្រើសរើសយកភិក្ខុសាមណេរដែលសិក្សាសាលាបាលី

នៅតាមវត្តនីមួយៗ មានសញ្ញាបត្រជាគ្រឿងសំគាល់ហើយ ទើបឲ្យចូលរៀនក្នុងសាលាធម្មទូតមានកំណត់ឆ្នាំតទៅទៀត ។

## ពួកសីលវតីនៅប្រទេសភូមា

ពួកស្រីអ្នករក្សាសីល (ដែលទុកដូចជាអ្នកបួស) នៅប្រទេសភូមា មាន ៣ ប្រភេទគឺ មួយប្រភេទរក្សាសីល ៥ មានសម្លៀកបំពាក់បែបពណ៌ខ្ចឹមខ្ទុរ, មួយប្រភេទរក្សាសីល ៨ មានសម្លៀកបំពាក់បែបពណ៌ផ្កាឈូក, មួយប្រភេទទៀតរក្សាសីល ១០ ដែលហៅថា អតិរេកសីលសម្រាប់គ្រហស្ថ, សុទ្ធតែប្រើសម្លៀកបំពាក់ពណ៌ផ្កាឈូកដែរ, ខ្ញុំបានសួរគេៗប្រាប់ថា ជ្រលក់ដោយគ្រាប់ជម្លក់ឲ្យមានពណ៌អម្ពុតប៉ុន្តែផ្សេងទៃពីពណ៌ត្រៃចីវរព្រះសង្ឃ ។ ស្ត្រីទាំងបីប្រភេទនេះ គេហៅថា សីលវតី ប្រែថា "ស្ត្រីអ្នកមានសីល" ឬហៅថា អនាគារិកា ប្រែថា "ស្ត្រីអ្នកគ្មានផ្ទះសម្បែង" ។ ពួកសីលវ័តីនេះមានច្រើនណាស់ក្នុងប្រទេសភូមា, ឃើញមាននៅតែដោយវត្តៗ, វត្តខ្លះមានសីលវ័តីនៅ ៣០ នាក់, ៥០ នាក់, ១០០ នាក់ក៏មាន ច្រើនជាងនេះក៏មាន តាមវត្តធំតូច ៗ វត្តណាដែលមានពួកសីលវ័តីនៅហើយ វត្តនោះឥតមានកុមារសាមណេរនៅប្របូកប្របល់ទេ, ពួកសីលវ័តីដែលមាននៅក្នុងវត្តនីមួយៗ ខ្លះរៀនកម្មដ្ឋាន, ខ្លះរៀនបាលី ព្រោះហេតុនោះបានជាមានពួកសីលវ័តីជាច្រើនចេះនិយាយបាលី, ចេះព្រះអភិធម្ម, ធ្វើជាធម្មកថិកា អ្នកសំដែងធម៌, បង្រៀនធម៌អាចដល់គ្នាឯងគ្នា ។

# ដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ

ថ្ងៃទី ២៩ ធ្នូ ១៩៥៤ សម្ដេចឪប្រតិភូខ្មែរត្រៃធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ ។ ម៉ោង ១៧.៣០ ចេញពីមហាកុដិ (កន្លែងសំណាក់ធ្វើសង្គាយនា) ដោយមានក្រុមនគរបាលជិះទោចក្រយានយន្តទីងក្នាក់ផ្លែរពជការជាច្រើន មានលោករដ្ឋលេខាធិការក្រសួងធម្មការជាដើមជូនដំណើរដកបដល់ស្ថានីយអាកាសយានមង្គលៈដូន ។ ម៉ោង ២០ សម្ដេចឪប្រតិភូទាំងអស់ឡើងអាកាសយាន (Thai airivays) ឆ្ពោះមកប្រទេសថៃ ។ ម៉ោង ២២,៣០ ដល់ស្ថានីយអាកាសយានដនមឿងក្រុងបាងកក, ចេញពីដនមឿងដោយរថយន្តឆ្ពោះទៅវត្តបាងហ្វាងឌិតក្រុងបាងកក, ឈប់សម្រាកនៅវត្តនោះអស់រយៈ ៥ ថ្ងៃ ។

ក្នុងរយៈប៉ុន្មានថ្ងៃ ដែលឈប់សម្រាកក្នុងក្រុងបាងកកនោះ ពួកពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថជាតិខ្មែរខ្លះ ថៃខ្លះ បានចូលទៅថ្វាយបង្គំគាល់សម្ដេចពុំស្ងួមានពេលស្រាក ។ ទៅឃុនព្រះទេពវេទី (ពជាគណៈ) វត្តសាមផ្សា (សាមព្រះយ៉ា) ក្រុងបាងកក បាននិមន្តសម្ដេចទៅថ្លែងការណ៍អប់រំព្រះសង្ឃថៃចំនួន ៧៥៦ អង្គ ដែលនៅក្នុងក្រុងខ្លះមកពីខេត្តក្រៅខ្លះ ប្រជុំគ្នាក្នុងសាលាវត្តសាមផ្សា ។ សម្ដេចបានទទួលនិមន្តទៅថ្លែងការណ៍អប់រំជាភាសាថៃចំពោះព្រះសង្ឃទាំងនោះអស់រយៈពីរលើក ។

នៅទីបំផុតចប់សេចក្ដីថ្លែងការណ៍អប់រំរបស់សម្ដេចហើយ ទើបលោ យុនព្រះទេពវេទី ឡើងថ្លែងសេចក្ដីប្រកាសប្រាប់ព្រះសង្ឃថៃទាំងអស់ថា សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ប្រទេសកម្ពុជា អង្គនេះជាអ្នកប្រាជ្ញមានកិត្តិស័ព្ទខ្ទរទៅក្នុងលោក, ដែលសម្ដេចថ្លែងការណ៍អម្បាញ់មិញនេះដោយយោបល់ត្រូវល្អណាស់ គួរយើងជឿស្ដាប់ហើយគោរពប្រតិបត្តិតាមកុំគប្បីភ្លេច តទៅអនាគត ៗ ថ្ងៃបន្ទាប់មក, លេខាធិការទី ១ នៃស្ថានទូតកូមានៅប្រចាំប្រទេសថៃក្រុងបាងកក បាននិមន្តសម្ដេចនិងព្រះសង្ឃខ្មែរ - លាវទៅទទួលភត្តនៅគេហដ្ឋានរបស់លោក ដើម្បីនឹងបានឱកាសប្រស្រ័យសំដែងសេចក្ដីគោរពតាមសមគួរដល់ការប្រស្រ័យ ៗ

ថ្ងៃទី ៤ មិថុនា ១៩៥៤ សម្ដេចនិងគណៈប្រតិភូខ្មែរត្រូវធ្វើដំណើរចេញពីក្រុងបាងកកមកប្រទេសកម្ពុជាវិញ ៗ គ្រានោះ ឯ. ឧ. អគ្គរាជ-ទូតខ្មែរ, ទូតកូមាដែលប្រចាំនៅប្រទេសថៃ, ព្រះសង្ឃជាតិខ្មែរ និងជាតិថៃ និងឧបាសកឧបាសិកាជាតិខ្មែរ-ថៃជាច្រើនបានជូនដំណើរដោយរថយន្ត មកកាន់ស្ថានីយអាកាសយានដនមឿង ៗ ម៉ោង ៨, ៣០ ឡើងអាកាសយាន ចេញឆ្ពោះមកក្រុងភ្នំពេញប្រទេសកម្ពុជា ៗ ម៉ោង ១១, ៣០ យន្តហោះដល់ស្ថានីយអាកាសយានពោធិចិនតុង ៗ ក្នុងវេលាយន្តហោះបន្ទាប់ចុះដល់ផ្ទៃផែនដីឈប់នៅនឹងថ្កល់, ឃើញ

ពួកឥស្សរជនទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើនគាំគាប់ មានសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា, ព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងឃោសនាការ, ឯកឧត្តមប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ, លោកប្រធានសមាគមមិត្តសាលាបាលី, ព្រះសង្ឃថេរានុត្ថេរៈ ភិក្ខុសាមណេរ និងគហបតីធំតូចជាច្រើន មួយអន្លើដោយក្រុមសមាជិកនៃពុទ្ធិកសមាគមនិងសមាគមមិត្តសាលាបាលីព្រមទាំងនារីរបាំមួយក្រុមផង ត្រៀមរង់ចាំទទួលដំណើរសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ដែលទើបត្រឡប់មកដល់ពីប្រទេសភូមា, ដោយមានរបៀបរៀបរយជាជួរជាសង្កាត់គួរឲ្យរមិលមើល គឺមាននារីរបាំ ៤ នាក់ឈរកាន់ជើងពានប្រាក់ក្រឡៃមាសពេញដោយផ្កាគ្រប់ពណ៌ចាំបាចផ្កានាំមុខ ៗ សម្តេចព្រះធម្មលិខិត, ព្រះតេជព្រះគុណព្រះពោធិវង្ស, ឯកឧត្តមរដ្ឋមន្ត្រី, ប្រធានសមាគមទាំងពីរព្រមទាំងព្រះសង្ឃនិងអស់លោកធំ តូច បានឈរដង្ហែគ្នាភ្ជាប់ពីដំណើរអាកាសយានមក ៗ ខណៈនោះ សម្តេចបាននិមន្តចុះពីអាកាសយានដោយព្រះហស្តប៉ីទ្រព្រះពុទ្ធរូបជាវិការៈនៃឈើម៉ៃសាក់ទឹបមាសមួយព្រះអង្គផង (ដែលបានមកពីប្រទេសភូមា) ៗ លោកប្រធានសមាគមមិត្តសាលាបាលី បានទទួលព្រះពុទ្ធរូបអំពីព្រហស្តសម្តេច, ផ្កាក៏ធ្លាក់ដោរដាសលើផ្លូវដែលមានព្រះសង្ឃនិងគ្រហស្ថឈរអម, សម្តេចនិមន្តដោយ

ដំណើរធម្មតា ៗ មុននឹងឡើងរថយន្ត សម្តេចបានមានថេរដីកាទៅកាន់ពុទ្ធបរិស័ទដោយសេចក្តីថា ខ្ញុំករុណា-អាត្មា មានសេចក្តីត្រេកអរជាអនេក ចំពោះសម្តេច, ឯកឧត្តម, អស់លោក-អ្នក ព្រះថេរានុត្ថេរៈ ភិក្ខុសាមណេរ ដែលបាននិមន្ត-អញ្ជើញមកក្នុងការទទួលដំណើរនេះ, ខ្ញុំករុណា-អាត្មាសូមប្រគេន សូមជូនពរចំពោះសម្តេច, ឯកឧត្តម, អស់លោក-អ្នកនឹងព្រះថេរានុត្ថេរៈគ្រប់អង្គ សូមឲ្យបានឋិតនៅក្នុងសុខភាពនឹងវឌ្ឍនភាពតរៀងទៅ ៗ

លុះចប់សេចក្តីថ្លែងអំណរដោយសង្ខេបនេះ សម្តេចនិមន្តឡើងគង់រថយន្ត ទាំងពុទ្ធបរិស័ទគ្រប់រូបក៏ឡើងរថយន្តជូនដំណើរសម្តេចដរាបដល់វត្តឧណ្ណាលោម ៗ នៅខាងមុខវិហារវត្តឧណ្ណាលោម, មានពុទ្ធបរិស័ទទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើន ឈរតម្រៀបគ្នាជាពីរជួរតាំងពីក្លោងទ្វារកំពែងវត្តដរាបដល់ប៉ាំខាងក្នុងកំពែងវិហារ ៗ សម្តេចចុះពីរថយន្តនិមន្តតាមដំណើរធម្មតាចូលគង់ក្នុងប៉ាំដែលគេតាក់តែងយ៉ាងស្អាតបំរុងទុក ៗ ពុទ្ធបរិស័ទទាំងអស់ក៏នាំគ្នាចូលមកធ្វើគារវកិច្ចចំពោះសម្តេចៗក៏មានថេរដីកាអំពីដំណើរទៅប្រទេសភូមាជាសេចក្តីខ្លី ៗ តាមគួរដល់វេលាហើយ ពុទ្ធបរិស័ទទាំងអស់ក៏ក្រាបថ្វាយបង្គំលាចេញទៅកាន់លំនៅវិញរៀងៗខ្លួន ៗ

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តពីសៀវភៅលេខ ៥ ឆ្នាំ ១៩៥៣)

---

សញ្ញាប័ត្រលេខ ៩១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ប៉ាន់ នាមឆាយា ព្រហ្មជោត កើតឆ្នាំកុរ អាយុ ៧៤ វស្សា ៣៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទៀវ-រ័យ នាមឆាយា សុវណ្ណសរ កើតឆ្នាំខាល អាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅរ៍-ឆេង នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៣២ វស្សា ១៣ ជាចៅអធិការ វត្តអង្គខ្ទារ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩១៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប-មុត នាមឆាយា ចន្ទត្ថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩១៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-គាំ នាមឆាយា ចន្ទត្ថេរ កើតឆ្នាំពេង អាយុ ២២ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-សារាយ នាមឆាយា សុវណ្ណកេសរ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាចៅអធិការវត្តអង្គតាពៅ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-កណ្ដៀន នាមឆាយា ជោតត្ថេរ កើតឆ្នាំមមី អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កង-ម៉ុល នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំម្សាញ់ អាយុ ២១ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុក ជា នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាចៅអធិការ វត្តបទុមសុរិយា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ិន-ង៉ិន នាមឆាយា សុធម្មសរ កើតឆ្នាំរកា អាយុ ៤២ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខេត-ជា នាមឆាយា គន្ធជោត កើតឆ្នាំរោង អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)